# ក្រសួងអប់រំយុវជន និងកីឡា

**MINISTRY OF EDUCATION YOUTH AND SPORTS**

# វិទ្យាស្ថាន វ៉ាន់ដា

**VANDA INSTITUTE**

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ

Angkor Beer Company Revenue Management

**ជំនាញ: សវនកម្ម**

**រៀបរៀងដោយ:ស៊ីម ស្រីរ័ត្ន**

**អត្តលេខ:** MVI20/011

**ឆ្នាំសិក្សា ៖ឆ្នាំ២០២២ - ២០២៤**

ក្រសួងអប់រំយុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ

Angkor Beer Company Revenue Management

ជំនាញ: សវនកម្ម

សាស្ត្រាចារ្យណែនាំ៖ បណ្ឌិត កង ឱម

ឆ្នាំសិក្សា ៖ឆ្នាំ២០២២ - ២០២៤

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**
**ប្រធានបទៈ ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ**

សាស្ត្រាចារ្យណែនាំ

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

សាស្ត្រាចារ្យណែនាំ

បណ្ឌិត កង ឱម

គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា និងស្រាវជ្រាវ
ប្រធាន

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

# មាតិកា

**ទំព័រ**


អារម្ភកថា ........ i
សេចក្តីថ្លែងអំណរគុណ ........ ii
អំណះអំណាង ........ iii
សេចក្តីសង្ខេបរបាយការណ៍ស្រាវជ្រាវ ........ iv


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
 ១.៤.១ ទំហំ និងដែនកំណត់ ........ ២
 ១.៤.២ វិសាលភាព ........ ២
១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៣
 ១.៥.១ វិធីសាស្រ្តដែលប្រើក្នុងការសរសេរ ........ ៣
 ១.៥.២ វិធីសាស្រ្តប្រមូលទិន្នន័យ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣-៤


## ជំពូកទី២
## រំលឹកទ្រឹស្តី


២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងចំណូល ........ ៥
 ២.១.១ និយមន័យនៃការស្រាវជ្រា ........ ៥
 ២.១.២ ប្រវត្តិនៃការគ្រប់គ្រង ........ ៥
 ២.១.៣ តួនាទីក្នុងការគ្រប់គ្រង ........ ៦
  ក. ជំនាញក្នុងការគ្រប់គ្រង ........ ៦
  ខ. មុខងារនៃការគ្រប់គ្រង ........ ៦-៧
២.២ ប្រភពចំណូលរបស់ក្រុមហ៊ុន ........ ៧
 ២.២.១ និយមន័យចំណូល ........ ៧
 ២.២.២ ប្រភេទនៃចំណូល ........ ៧

២.៣ គោលការណ៍ក្នុងការគ្រប់គ្រងចំណូល ........ ៨
២.៣.១ និយមន័យគោលការណ៍........ ៨
២.៣.២ ប្រវត្តិពាក្យគោលការណ៍........ ៨
២.៣.៣ ការកំណត់គោលការណ៍........ ៨-៩
២.៤ បញ្ហាប្រឈមក្នុងការគ្រប់គ្រងប្រាក់ចំណូល ........ ៩
២.៤.១ និយមន័យនៃបញ្ហាប្រឈម ........ ៩
២.៤.២ កត្តាដែលធ្វើឲ្យការគ្រប់គ្រងមានបញ្ហា........ ៩
ក. កត្តាធនធានមនុស្ស ........ ៩
ខ. កត្តាបច្ចេកទេស ........ ១០

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនស្រាបៀរអង្គរ ........ ១១
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុនស្រាបៀរអង្គរ........ ១១-១២
ក. ទីតាំងក្រុមហ៊ុនស្រាបៀរអង្គរ ........ ១២
៣.១.២ គោលនយោបាយស្រាបៀរអង្គរ........ ១៣-១៤
៣.១.៣ បេសកកម្ម និងទស្សនៈវិស័យ ........ ១៤
ក. បេសកកម្ម........ ១៤-១៥
១. រូបរាងថ្មីរបស់ស្រាបៀរអង្គរ ........ ១៥-១៦
២. យុទ្ធសាស្ត្រទីផ្សារ ........ ១៦-១៧
ខ. ទស្សនៈវិស័យ........ ១៧-១៨
៣.២ ប្រភពចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ........ ១៨
៣.៣ គោលការណ៍គ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ ........ ១៨-១៩
៣.៣.១ វិធីសាស្ត្រក្នុងការគ្រប់គ្រងចំណូល........ ១៩
១. តួនាទីអ្នកគ្រប់គ្រង ........ ១៩-២០
២. តួនាទីគណនេយ្យករ........ ២០-២១
៣.៤ បញ្ហាប្រឈមក្នុងការគ្រប់គ្រងប្រាក់ចំណូល ........ ២១
៣.៤.១ ប្រព័ន្ធគ្រប់គ្រងក្នុងក្រុមហ៊ុន ........ ២១-២២
ក. បញ្ហាខាងក្នុង........ ២២
ខ. បញ្ហាខាងក្រៅ........ ២៣

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគចំណុចខ្លាំង ........................................ ២៨
៤.១ ការវិភាគចំណុចខ្សោយ ........................................ ២៨-២៩

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន........................................ ៣០
៥.១ ការផ្តល់អនុសាសន៍ ........................................ ៣១

# អារម្ភកថា

នាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញសវនកម្មជំនាន់ទី២០បានធ្វើការស្រាវជ្រាវរៀបចំចងក្រងចេញជារបាយការណ៍ស្តីពី"**ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ**" ក្នុងគោលបំណងដើម្បីពង្រីកនូវចំណេះដឹងថ្មី ឆ្លើយតបទៅនឹងបច្ចេកទេស និងវិទ្យាសាស្ត្រប្រកបដោយប្រសិទ្ធភាពគំនិតច្នៃប្រឌិតភាពទទួលខុសត្រូវក្រមសីលធម៌ និងមនសិការការងារដែលទាក់ទងទៅនឹងការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាពមិនថានៅក្នុងក្រុមគ្រួសារ ក្រុមហ៊ុន រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ធនាគារជាដើម។

យើងបានដឹងហើយថា សព្វថ្ងៃនេះប្រទេសកម្ពុជាកំពុងតែមានការរីកចម្រើនស្ទើរគ្រប់វិស័យ មិនថាពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម ទេសចរណ៍ សំណង់ ឬជាវិស័យធនាគារ គឺកំពុងតែមានការប្រកួតប្រជែងយ៉ាងខ្លាំងក្លា។ ហើយភាពរឹងមាំរបស់វិស័យនីមួយៗ គឺត្រូវពឹងផ្អែកទៅលើអ្នកដឹកនាំល្អដែលអាចធ្វើការរៀបចំផែនការយុទ្ធសាស្ត្របានត្រឹមត្រូវជាពិសេស គឺផែនការគ្រប់គ្រងនឹងចាត់ចែងផ្នែកហិរញ្ញវត្ថុបានច្បាស់លាស់។

ដោយយល់ឃើញថា ការគ្រប់គ្រងហិរញ្ញវត្ថុគឺជារឿងមួយដ៏សំខាន់សម្រាប់បុគ្គល ក្រុមហ៊ុន រោងចក្រ សហគ្រាស ឬអាជីវកម្មផ្សេងៗ ទើបខ្ញុំក៏បានសម្រេចចិត្តលើកយកប្រធានបទស្តីអំពី"**ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ**" មកបង្ហាញដើម្បីជាប្រយោជន៍ទៅដល់អ្នកដែលត្រូវការចង់ដឹង និងយល់ច្បាស់អំពីរបៀបគ្រប់គ្រងប្រាក់ចំណូលខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។

ជាទីបញ្ចប់នាងខ្ញុំ សូមមេត្តាខន្តីអភ័យទោសពីសំណាក់លោកគ្រូ អ្នកគ្រូ រាមច្បង និងមិត្តអ្នកអាននូវរាល់កំហុសឆ្គង ដែលកើតមានដោយអចេតនានៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយនាងខ្ញុំរីករាយនិងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនាដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានការភាពល្អប្រសើរ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ស៊ីម ស្រីរ័ត្ន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី២០ជំនាញសវនកម្មនៃវិទ្យាស្ថានវ៉ាន់ដា។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

លោកឪពុកនិងអ្នកម្តាយដែលបានផ្តល់កំណើតហើយខិតខំបីបាច់ថែរក្សាកូនព្រមទាំងផ្គត់ផ្គង់ដល់កូនសព្វបែបយ៉ាងខិតខំលើកទឹកចិត្តកូនក្នុងការសិក្សាតាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះនិងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ នៃវិទ្យាស្ថានវ៉ាន់ដាដែលជានិច្ចកាលតែងតែផ្តល់នូវការលើកទឹកចិត្ត អនុគ្រោះដល់នាងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យបណ្ឌិត **ភាន ឱម** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃរបស់ លោកក្នុងការចង្អុលបង្ហាញគ្រប់វិធីសាស្ត្រ និងផ្តល់ជាគំនិតក្នុងការសិក្សាស្រាវជ្រាវដល់និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ទាំងអស់ដើម្បីចងក្រងនូវ កិច្ចការស្រាវជ្រាវនេះឱ្យរឹតតែមានភាពល្អប្រសើរឡើង។

ជាទីបញ្ចប់ នាងខ្ញុំសូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឲ្យជួបតែសេចក្តីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការដ៏មហាប្រសើរ គឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

នាងខ្ញុំ **ស៊ីម ស្រីរ័ត្ន** សូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថារបាយការណ៍ស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់នាងខ្ញុំដោយគ្មានពាក់ព័ន្ធជាមួយរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងរបាយការណ៍ស្រាវជ្រាវរបស់គេឡើយ។

ភ្នំពេញ ថ្ងៃទី............ខែ.............ឆ្នាំ២០២៤

**ហត្ថលេខា**

**ស៊ីម ស្រីរ័ត្ន**

# សេចក្ដីសង្ខេបនៃការស្រាវជ្រាវ

ដើម្បីបំពេញទៅតាមលក្ខខ័ណ្ឌរបស់វិទ្យាស្ថានវ៉ាន់ដា និងដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលបានសិក្សាកន្លងមកនេះ នាងខ្ញុំជានិស្សិតដែលទទួលបានការជ្រោមជ្រែងយ៉ាងកក់ក្ដៅ ពីក្រុមហ៊ុនស្រាបៀរអង្គរបានប្រមូលផ្ដុំនូវចំណេះដឹងគ្រប់បែបយ៉ាងថែមទាំងទទួលបាននូវការផ្ដល់មតិយោបល់ បទពិសោធន៍ផ្សេងៗ និងការសិក្សាកន្លងមកក្នុងគោលបំណងមួយយ៉ាងសំខាន់គឺ ការរៀបចំចងក្រងឡើងនូវរបាយការណ៍មួយក្រោមប្រធានបទស្ដីពី"ការគ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ"។ របាយការណ៍នេះផ្ដោតទៅលើការសិក្សាស្រាវជ្រាវនិងប្រៀបធៀបទ្រឹស្ដីទៅនឹងការអនុវត្តន៍ជាក់ស្ដែងរបស់ក្រុមហ៊ុនដូចនាងខ្ញុំបានលើកយក៤ចំណុចដូចខាងក្រោម៖

- ប្រភពចំណូលរបស់ក្រុមហ៊ុន
- វិធីសាស្ត្រក្នុងការគ្រប់គ្រងចំណូល
- ការវិភាគរបាយការណ៍ចំណូល
- បញ្ហាក្នុងការគ្រប់គ្រង

ក្នុងការសិក្សាស្រាវជ្រាវនិងប្រៀបធៀបរបស់ក្រុមហ៊ុននាងខ្ញុំបានបង្ហាញពីភាពជាក់ស្ដែងនៃការអនុវត្តន៍របស់ក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាពដែលធ្វើឲ្យក្រុមហ៊ុនទទួលបានសុក្រឹតភាពលើចំណុចមួយចំនួនដូចជាការចាត់ថ្នាក់ចំណូលរបស់លក្រុមហ៊ុនមានលក្ខណៈត្រឹមត្រូវនិងប្រសើរជាងមុនការរៀបចំផែនការគ្រប់គ្រងព្រមទាំងការទូទាត់ចំណាយបានម៉ត់ចត់ជាដើម។ ក្រៅពីនេះក្រុមហ៊ុនក៏មានចំណុចខ្វះខាតផ្សេងទៀតទៅលើបញ្ហាបំណុលដែលអតិថិជនជំពាក់ និងការចំណាយខ្ជះខ្ជាយជាដើម។

ដូចនេះ ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវរួចមកក្រុមហ៊ុនគួរតែធ្វើការកែលម្អចំណុចខ្វះខាតទាំងនេះឱ្យបានល្អប្រសើរឡើងដើម្បីមានលទ្ធភាពក្នុងការទូទាត់ទៅលើចំណាយក៏ដូចជាស្វែងរកបន្ថែមនូវប្រាក់ចំណេញឱ្យបានកាន់តែច្រើន។ ម្យ៉ាងទៀតក្រុមហ៊ុនគួរតែរៀបចំប្រព័ន្ធគណនេយ្យឱ្យបានត្រឹមត្រូវ និងរៀបចំការគ្រប់គ្រងចំណូលចំណាយឲ្យបានច្បាស់លាស់ព្រោះវាជាកត្តាមួយយ៉ាងសំខាន់ ក្នុងដំណើរការអាជីវកម្មដើម្បីទទួលបានភពជោគជ័យនិងភាពរីកចម្រើន។

# ជំពូកទី១
# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

គ្រប់ប្រទេសជាតិទាំងអស់នៅលើសកលលោក មិនថាប្រទេសណាក៏ដូចប្រទេសណាដែរតែងតែពង្រឹង និងអភិវឌ្ឍន៍ប្រទេសជាតិរបស់ខ្លួនឱ្យមានការរីកចម្រើនលើគ្រប់វិស័យទាំងអស់។មិនខុសគ្នានោះដែរប្រទេសកម្ពុជាយើងក៏កំពុងតែអភិវឌ្ឍន៍ឱ្យមានភាពលូតលាស់និងរីកចម្រើនជាលំដាប់ផងដែរ។តែដោយសារប្រទេសកម្ពុជាធ្លាប់ជួបប្រទះនឹងសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំកន្លងមកទើបធ្វើឱ្យមានការខ្វះខាតនូវទ្រព្យសម្បត្តិហេដ្ឋារចនាសម្ព័ន្ធនិងបាត់បង់ធនធានមនុស្សអស់ជាច្រើន។មិនតែប៉ុណ្ណោះវាបានធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអភិវឌ្ឍន៍ប្រទេសជាតិថែមទៀតផង។យ៉ាងណាមិញបើយើងក្រឡេកមកមើលពីស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្នវិញឃើញថាប្រទេសកម្ពុជាកំពុងតែរីកលូតលាស់ទៅមុខជាលំដាប់លើគ្រប់វិស័យទាំងអស់។ម្យ៉ាងទៀតសេដ្ឋកិច្ចប្រទេសកម្ពុជាក៏មានការរីកចម្រើនខ្លាំងដោយសារមានក្រុមហ៊ុននិងរោងចក្រជាច្រើនដែលរួមចំណែកក្នុងការជួយពន្លឿនសេដ្ឋកិច្ចជាតិឱ្យរីកចម្រើនបានយ៉ាងឆាប់រហ័ស។ក្នុងនោះដែរគេបែងចែក ក្រុមហ៊ុនជាបីប្រភេទគឺក្រុមហ៊ុនពាណិជ្ជកម្មក្រុមហ៊ុនសេវាកម្មនិងក្រុមហ៊ុនផលិតកម្ម។ ស្របគ្នានេះដែរក្រុមហ៊ុនផលិតកម្មក៏ដើរយ៉ាងសំខាន់ក្នុងការផលិតនិងបំពេញតម្រូវការរបស់មនុស្សគ្រប់រូបផងដែរ។

បច្ចុប្បន្ននេះគ្រប់ក្រុមហ៊ុនផលិកម្មទាំងអស់បានខិតខំយកចិត្តទុកដាក់រកវិធីសាស្ត្រណាដែលមានប្រសិទ្ធភាពខ្ពស់ដែលអាចបំពេញនូវរាល់តម្រូវការរបស់អតិថិជនបានច្រើននិងទាន់តម្រូវការរបស់អ្នកប្រើប្រាស់។ ប៉ុន្តែទន្ទឹមនឹងនោះផងដែរម្ចាស់ក្រុមហ៊ុននិងអ្នកគ្រប់គ្រងក៏ត្រូវមានគោលការណ៍មួយចំនួនផងដែរក្នុងការគ្រប់គ្រងឱ្យមានភាពរលូនជាពិសេសគឺការគ្រប់គ្រងប្រាក់ចំណូលតែម្តងត្រូវតែធ្វើឱ្យមានភាពច្បាស់លាស់ទើបមិនធ្វើឱ្យមានការខាតបង់ទ្រព្យសម្បត្តិ ហើយក្រុមហ៊ុនក៏អាចដំណើរការទៅបានយ៉ាងល្អ។ ការគ្រប់គ្រងប្រាក់ចំណូលវាមានភាពចាំបាច់ណាស់សម្រាប់ក្រុមហ៊ុននីមួយៗដែលត្រូវយកចិត្តទុកដាក់ បង្កើនការប្រុងប្រយ័ត្ននិងចេះចាត់ចែងឱ្យបានច្បាស់លាស់មុននឹងចំណាយទៅលើអ្វីមួយ។ ជាធម្មតាគ្រប់ក្រុមហ៊ុន ទាំងអស់តែងតែមានគោលការណ៍ផ្សេងៗគ្នាក្នុងការគ្រប់គ្រងប្រាក់ចំណូលរបស់ខ្លួនដូចនេះហើយ ការគ្រប់គ្រងនេះវាជាកត្តាមួយដ៏សំខាន់ដែលម្ចាស់ក្រុមហ៊ុន និងអ្នកចាត់ចែងផ្នែកចំណូលត្រូវយកចិត្តទុក ដាក់។

បច្ចុប្បន្នការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនមួយចំនួនមិនទាន់មានភាពរលូននៅឡើយទេព្រោះជាក់ស្តែងឃើញនៅមានភាពទន់ខ្សោយនិងមិនទាន់បានអនុវត្តន៍ឱ្យឆ្លើយតបទៅតាមគោលការណ៍របស់ក្រុមហ៊ុន។ ដូចនេះអ្នកគ្រប់គ្រងគួរតែពង្រឹងនូវការអនុវត្តតាមគោលការណ៍ឱ្យកាន់តែប្រសើរឡើង ដើម្បីឱ្យក្រុមហ៊ុន ដំណើរការបានដោយមិនមានភាពរអាក់រអួល។ ម្យ៉ាងទៀតអ្នកអនុវត្តន៍ការងារផ្ទាល់ ក៏ត្រូវមានទំនួលខុសត្រូវ ចំពោះខ្លួនឯងស្គាល់ពីតួនាទីរបស់ខ្លួនឱ្យបានច្បាស់លាស់ហើយក៏ត្រូវពង្រីកសមត្ថភាព របស់ខ្លួនឱ្យបានច្រើនឡើងទើបអាចគ្រប់គ្រងការងារនោះបានល្អ។ ដោយមើលឃើញពីសារៈសំខាន់នៃ ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន ទើបនាងខ្ញុំជ្រើសរើសប្រធានបទ **“ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន ស្រាបៀរអង្គរ”**យកមកធ្វើការសិក្សាស្រាវជ្រាវ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "**ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ**"ឱ្យបានកាន់តែច្បាស់លាស់និងស៊ីជម្រៅ នាងខ្ញុំក៏មាននូវចំណោទបញ្ហាមួយចំនួនដែលបានចោទឡើងថា៖

- តើចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ ទទួលបានតាមរយៈប្រភពណាខ្លះ?
- តើក្រុមហ៊ុនស្រាបៀរអង្គរមានគោលការណ៍អ្វីខ្លះ ដើម្បីគ្រប់គ្រងប្រាក់ចំណូលឱ្យមានប្រសិទ្ធភាពខ្ពស់?
- តើដំណើរការនៃការគ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុនមានជួបប្រទះបញ្ហាអ្វីខ្លះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះគឺមានគោលបំណងដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីការគ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរនិងដើម្បីស្វែងយល់ពីស្ថានភាពជាក់ស្តែងរបស់ ក្រុមហ៊ុន។ ម្យ៉ាងទៀតការស្រាវជ្រាវនេះគឺដើម្បីរួមចំណែកក្នុងការកែលម្អនូវចំណុចខ្វះខាតមួយចំនួន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងប្រាក់ចំណូល និងស្វែងយល់ពី៖

- ស្ថានភាពទូទៅរបស់ក្រុមហ៊ុនស្រាបៀរអង្គរ
- ស្វែងយល់អំពីប្រវត្តិរបស់ក្រុមហ៊ុនស្រាបៀរអង្គរ
- វិធីសាស្រ្តក្នុងការគ្រប់គ្រងប្រាក់ចំណូល
- ដំណើរការនៃការគ្រប់គ្រង និងបញ្ហាប្រឈមរបស់ក្រុមហ៊ុន
- ចំណុចខ្លាំងចំណុចខ្សោយរបស់ក្រុមហ៊ុនស្រាបៀរអង្គរ
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍
- បរិបទផ្សេងៗរបស់ក្រុមហ៊ុន

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ ដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់តែទៅលើការគ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរដែលស្ថិតនៅសាខាពោធិ៍ចិនតុងរាជធានីភ្នំពេញតែប៉ុណ្ណោះ។

### ១.៤.២ វិសាលភាព

ក្នុងការស្រាវជ្រាវប្រធានបទនេះ យើងបានកំណត់ពីវិសាលភាពដោយយកទិន្នន័យនៅក្នុងឆ្នាំ២០២១ តែប៉ុណ្ណោះ ព្រោះដើម្បីឱ្យការស្រាវជ្រាវមានលក្ខណៈច្បាស់លាស់ និងមានពេលវេលាគ្រប់គ្រាន់។

## ១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ

### ១.៥.១ វិធីសាស្រ្តដែលប្រើក្នុងការសរសេរ

វិធីសាស្រ្តដែលបានយកមកប្រើប្រាស់ក្នុងការសរសេរមាន ២ វិធីសាស្រ្តគឺ៖

- វិធិសាស្រ្តដំបូង ឬទិន្នន័យទីមួយ(Primary Data)
- វិធីសាស្រ្តបន្ទាប់បន្សំ ឬទិន្នន័យទីពីរ(Secondly Data)

### ១.៥.២ វិធីសាស្រ្តប្រមូលទិន្នន័យ

\+ ទិន្នន័យចំបង ( Primary Data )

គឺជាប្រភេទទិន្នន័យដែលបានមកដោយផ្ទាល់ពីការចុះសម្ភាស៍ និងសាកសួរពីប្រធានផ្នែកហិរញ្ញវត្ថុ ផ្នែកគណនេយ្យដែលពាក់ព័ន្ធក្នុងក្រុមហ៊ុនស្រាបៀរអង្គរ

\+ ទិន្នន័យបន្ទាប់បន្សំ (Secondly Data)

ជាទិន្នន័យបានមកពីការស្រាវជ្រាវ លើឯកសារមួយចំនួនដូចជាៈ

- ឯកសារនៅក្នុងបណ្ណាល័យ
- Google, Website…
- ឯកសារមួយចំនួនដែលមាននៅក្នុងក្រុមហ៊ុនស្រាបៀរអង្គរ
- សៀវភៅរបាយការណ៍ ផ្សេងៗដែលមានស្រាប់

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះគឺមានសារៈសំខាន់ណាស់ហើយថែមទាំងបានផ្តល់នូវគុណប្រយោជន៍យ៉ាងច្រើនដល់យើងខ្ញុំដូចជាៈ

- យល់ដឹងពីស្ថានភាពទូទៅ នៃការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនផលិតកម្ម
- អាចឱ្យយើងដឹងពីទិន្នន័យនៃសាច់ប្រាក់ និងវិធីសាស្រ្តក្នុងការគ្រប់គ្រងចំណូល
- ប្រសិទ្ធភាពនៃការរៀបចំគំរោងគ្រប់គ្រងចំណូល
- ជួយបង្កើនចំណេះដឹងឱ្យយើងបានកាន់តែច្រើនឡើង និងទទួលបានបទពិសោធន៍ថ្មីៗពីការស្រាវជ្រាវ
- ទុកជាឯកសារសម្រាប់និស្សិត និងអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗ
- ទុកជាឯកសារមួយសម្រាប់ដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធ និងបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួនទៀត
- ផ្តល់គំនិតថ្មីៗ...

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានបែងចែកជា ៥ជំពូកដូចខាងក្រោមៈ

**\+ ជំពូកទី១ ៖ សេចក្តីផ្តើម**

ជំពូកនេះបង្ហាញពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ទំហំ ដែនកំណត់ វិសាលភាព វិធីសាស្រ្ត សារៈសំខាន់ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**\+ ជំពូកទី២ ៖ ការរំលឹកទ្រឹស្តី**

និយាយពីការលើកឡើងទ្រឹស្តីមួយចំនួនដែលបានសិក្សាកន្លងមក ហើយទាក់ទងនឹងប្រធានបទ "**ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ**"សាខាពោធិ៍ចិនតុង។

**\+ ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវ**

ជំពូកនេះ គឺបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវរបស់ប្រធានបទខាងលើនិងវិភាគទៅលើគោលការណ៍របស់ក្រុមហ៊ុនការអនុវត្តន៍ការងារគ្រប់គ្រងប្រាក់ចំណូល និងវិភាគលើប្រសិទ្ធិភាពនៃការអនុវត្តគោលនយោបាយគ្រប់គ្រងចំណូលក្នុងក្រុមហ៊ុនស្រាបៀរអង្គរ។

**\+ជំពូកទី៤ ៖ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ**

សិក្សាលើទិន្នន័យនិងលទ្ធផលដែលទទួលបានពីការស្រាវជ្រាវនិងវិភាគរកនូវចំណុចខ្លាំងចំណុចខ្សោយរបស់ប្រធានបទ។

+ **ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

បន្ទាប់ពីធ្វើការស្រាវជ្រាវនិងវិភាគរួចមកយើងបានធ្វើការសន្និដ្ឋានដែលក្នុងនោះមានការផ្តល់ មតិយោបល់ពីគ្រូដឹកនាំធ្វើរបាយការណ៍ស្រាវជ្រាវដើម្បីឱ្យការស្រាវជ្រាវនេះទៅមុខបានយ៉ាងរលូន និងសម្រេចបានជោគជ័យ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ការគ្រប់គ្រងចំណូល

## ២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងចំណូល

### ២.១.១ និយមន័យនៃការគ្រប់គ្រង

ការគ្រប់គ្រងគឺជាដំណើរការនៃការធ្វើផែនការការចាត់ចែងការដឹកនាំនិងត្រួតពិនិត្យទៅលើការប្រើប្រាស់ធនធានមនុស្សនៅក្នុងអង្គភាពឬក្រុមហ៊ុនមួយដើម្បីឈានទៅដល់គោលដៅក្នុងអង្គភាព។[1]

ការគ្រប់គ្រងគឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្សនិងធនធានដទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព។[2]

ការគ្រប់គ្រងគឺជាការទទួលខុសត្រូវមួយដ៏លំបាកវាទាមទារឱ្យអ្នកគ្រប់គ្រងចាំបាច់ត្រូវមាន សមត្ថភាពយល់ដឹងខ្ពស់រហ័សរហួនប្រកបដោយភាពប៉ិនប្រសប់និងមានចំណេះដឹងទូលំទូលាយបើទោះបីជាយ៉ាងនេះក៏ដោយក៏នៅមានអ្នកគ្រប់គ្រងខ្លះទទួលបានជោគជ័យហើយអ្នកគ្រប់គ្រងខ្លះបរាជ័យផងដែរ។[3]

ការគ្រប់គ្រងជាផ្នែកមួយសំខាន់ខ្លាំងណាស់សម្រាប់ក្រុមហ៊ុនឬអង្គភាព។កាលណាការគ្រប់គ្រងល្អ ក្រុមហ៊ុនឬអង្គភាពនោះក៏ដំណើរការល្អទៅតាមនឹងដែរ។ តែជាក់ស្តែងនៅក្នុងក្រុមហ៊ុនណាក៏ដូចជាក្រុមហ៊ុន ណាដែរ ដំណើរការនៃការធ្វើអាជីវកម្មតែងតែជួបប្រទះនូវបញ្ហាមួយចំនួនដោយជៀសពុំបាន។

ហេតុដូចនេះហើយទើបគ្រប់ក្រុមហ៊ុនទាំងអស់បែងចែកតួនាទីនិងស្វែងរកអ្នកគ្រប់គ្រងដែលមានជំនាញក្នុងការគ្រប់គ្រងឱ្យបានច្បាស់លាស់។

### ២.១.២ ប្រវត្តិនៃការគ្រប់គ្រង

គេបានរកឃើញប្រវត្តិនៃការគ្រប់គ្រងធនធានមនុស្សនៅក្នុងប្រទេសអង់គ្លេសដែលទីនោះពួកជាងកំបោរ ជាងឈើ ជាងសម្លាប់ស្បែកសត្វ និងពួកអ្នកធ្វើខាងការងារសប្បិកម្ម បានប្រមូលគ្នាជាក្រុមហ៊ុនអាជីពសង្គមកាលពីសម័យនោះ។ពួកគេប្រើប្រាស់ការរស់នៅជាក្រុមដោយឯកភាពបែបនេះដើម្បីការងារមានភាពងាយស្រួលដល់ការប្រកបការងារប្រចាំថ្ងៃរបស់ពួកគេ។ការរស់នៅបែបនេះបានរីកចម្រើនឡើងជាមួយការមកដល់នៃការបដិវត្តន៍ឧស្សាហកម្មនៅចុងសតវត្សទី១៨ដែលបានក្លាយជាមូលដ្ឋានសម្រាប់សង្គមឧស្សាហកម្មដ៏សាំញ៉ាំថ្មីមួយ។ការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រ (Scientific) និងការងារសុខមាលភាព (Welfare Work) បានក្លាយជាតំណាងឱ្យរបៀបពីរដែលបាន ចាប់ផ្តើមលេចឡើងព្រមជាមួយគ្នា នៅសតវត្សទី១៩ ហើយ ក៏លាយចូលគ្នាជាមួយចិត្តសាស្ត្រឧស្សាហកម្ម (Industrial psychology) តាំងពីសម័យកាលនៃសង្គ្រាម លោកមក។ ការគ្រប់គ្រងបែបវិទ្យាសាស្ត្រជាតំណាងនៃការប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាដែលគ្មាន ប្រសិទ្ធភាពក្នុងកិច្ចការពលកម្មនិងការគ្រប់គ្រងជាចំបងតាមរយៈវិធីសាស្ត្រផ្សេងៗ ការសិក្សាពីចលនា ដំណើរការនិងពេលវេលាព្រមទាំងលក្ខណៈឯកទេសកម្មផងដែរ។ ក្បួនចិត្តសាស្ត្រឧស្សាហកម្មជាការ ប្រើប្រាស់នូវគោលការណ៍សំដៅដើម្បីបង្កើនឡើងនូវសមត្ថភាពពលករក្នុងការបំពេញការងារឱ្យមាន ប្រសិទ្ធិភាព។ បិតានៃការគ្រប់គ្រង

[1] https://sokankeng.wordpress.com/ (01-12-23)
[2] https://clubniset.woidpress.com (01-12-23)
3 https://web.facebook.com/461028084731829/posts/658555458312423/ (14-01-24)

បែបវិទ្យាសាស្ត្រមានឈ្មោះល្បីនោះគឺ លោក Frederick Winslow Taylor។ លោកជាវិស្វករបស់ក្រុមហ៊ុន Midvale Steel Worksនៅទីក្រុងហ្វីឡាដែលហ្វីយ៉ា ពីឆ្នាំ ១៨៧៨ ដល់ឆ្នាំ ១៨៩០។[4]

**២.១.៣ តួនាទីនៃការគ្រប់គ្រង**

គេចែកតួនាទីនៃការគ្រប់គ្រងជាបីប្រភេទគឺ តួនាទីរវាងបុគ្គល តួនាទីក្នុងការជូនដំណឹង និងតួនាទីក្នុងការសម្រេចចិត្ត។

**១. តួនាទីរវាងបុគ្គល៖** ប្រធានគ្រប់គ្រងមានតួនាទីក្នុងការទាក់ទងជាមួយមនុស្សខាងក្នុង និងខាងក្រៅក្រុមហ៊ុន។ ក្នុងនោះក៏មានតួនាទី ៣ដែរ

- តួនាទីតំណាង
- តួនាទីភាពជាអ្នកដឹកនាំ
- តួនាទីទំនាក់ទំនង

**២. តួនាទីក្នុងការជូនដំណឹង៖** ប្រធានគ្រប់គ្រងមានតួនាទីស្វែងរកព័ត៌មាន និងជូនដំណឹងទៅបុគ្គលិកខាងក្នុងក្រុមហ៊ុន។ ហើយក្នុងនោះក៏មានតួនាទី ៣ទៀតគឺ៖

- តួនាទីក្នុងការតាមដាន
- តួនាទីក្នុងការផ្សព្វផ្សាយ
- តួនាទីជាអ្នកដឹកនាំពាក្យ

**៣.តួនាទីក្នុងការសម្រេចចិត្ត៖**ប្រធានគ្រប់គ្រងមានតួនាទីក្នុងការប្រមូលព័ត៌មានដើម្បីសម្រេចផែនការនិងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនសម្រាប់ទិសដៅក្រុមហ៊ុន។ក្នុងនោះដែរមានតួនាទី៤ទៀតផងដូចជា៖

- តួនាទីជាសហគ្រិន
- តួនាទីដោះស្រាយបញ្ហាដែលរំខាន
- តួនាទីក្នុងការបែងចែកធនធាន
- តួនាទីចរចារ។

❖ ក្រៅពីការបែងចែកតួនាទីក្នុងការគ្រប់គ្រងគេក៏បានបែងចែកពីជំនាញនៃការគ្រប់គ្រង និងមុខងារមួយចំនួនផ្សេងទៀតដូចខាងក្រោម៖

**ក. ជំនាញនៃការគ្រប់គ្រង**

១. ជំនាញប្រាជ្ញា៖ ទាក់ទងនឹងបញ្ញាផ្ទាល់របស់បុគ្គលហើយអ្នកគ្រប់គ្រងក៏ត្រូវចេះ បង្កើនប្រសិទ្ធភាពតាមរយៈអាកប្បកិរិយា ចំណេះដឹង និងបច្ចេកវិទ្យាជាដើម។

២. ជំនាញប្រើមនុស្ស៖ គឺជាសមត្ថភាពនៃការយល់ចិត្តមនុស្ស និងការលើកទឹកចិត្តអ្នកដទៃ។

៣. ជំនាញបច្ចេកទេស៖ គឺជាសមត្ថភាពក្នុងការអនុវត្តចំណេះដឹង និងបច្ចេកទេស។

**ខ. មុខងារនៃការគ្រប់គ្រង**

កាលពីមុនសតវត្សទី២០ មុខងារនៃការគ្រប់គ្រងត្រូវបានបែងចែកជា៥ គឺ៖

- ការធ្វើផែនការ
- ការរៀបចំចាត់ចែង

4 *វិទ្យាស្ថានវ៉ាន់ដារបាយការណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតឈ្មោះសៀប គឹមមាយ ទំព័រទី៥*

- ការបញ្ជា
- ការសម្របសម្រួល និង
- ការត្រួតពិនិត្យ។

ប៉ុន្តែបច្ចុប្បន្នគេបានបង្រួមមកនៅត្រឹម ៤ វិញដូចជាៈ

- ការធ្វើផែនការៈ គិតពីការធ្វើផែនការនៅក្នុងតួនាទីគ្រប់គ្រង គឺគិតថាតើដំណើរការ នៃគោលដៅនិងសកម្មភាពសមស្របណាគួរជ្រើសយកដើម្បីបន្តទៅមុខសកម្ម ហើយបន្ទាប់ មកកំណត់ថាតើត្រូវប្រើយុទ្ធសាស្ត្រអ្វីខ្លះ សកម្មភាពអ្វីធនធានអ្វីខ្លះដើម្បីសម្រេច គោលដៅ។
- ការរៀបចំចាត់ចែងៈ នេះជាដំណើរការនៃការបង្កើតទំនាក់ទំនងរវាងកម្មករនិយោជិតដែលអនុញ្ញាតឱ្យកម្មករនិយោជិតធ្វើការជាមួយគ្នាដើម្បីសំរេចបានគោលដៅរបស់អង្គភាព ដោះស្រាយទំនាស់និងសម្រួលបញ្ហា ជួយគាំទ្រពេលមានវិបត្តិ។
- ការដឹកនាំៈ មុខងារនេះពាក់ព័ន្ធនឹងការបង្ហាញចក្ខុវិស័យ បង្កើនថាមពល និងបំផុសលើកទឹកចិត្តមនុស្សក្នុងក្រុមដោយប្រើចក្ខុវិស័យ បង្កើនឥទ្ធិពលវិជ្ជមាន សិល្បៈបញ្ចុះបញ្ចូល និងជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពដើម្បីឱ្យផលិតភាពការងារកើន និងគ្រប់គ្នាធ្វើការបានដោយរលូន។
- ការត្រួតពិនិត្យៈ វាយតម្លៃថាតើអ្នកកំពុងតែសំរេចគោលដៅរបស់អ្នកបានល្អប្រសើរធ្វើឱ្យប្រសើរឡើងនូវការអនុវត្តសកម្មភាពចាត់វិធានការយ៉ាងដូចម្តេច។ ដាក់ដំណើរការឱ្យបានត្រឹមត្រូវដើម្បីជួយអ្នកបង្កើតស្តង់ដារដូច្នេះអ្នកអាចវាស់ប្រៀបធៀប និងធ្វើការសម្រេចចិត្ត។

ដោយសារតែមានការបែងចែកតួនាទី ជំនាញ និងមុខងារនៃការគ្រប់គ្រងទាំងនេះហើយ ទើបធ្វើ ឱ្យមានការរៀបចំកត្តាផលិតកម្មប្រមូលផ្តុំ និងរៀបចំធនធានរួមបញ្ចូលគ្នាបានយ៉ាង មានប្រសិទ្ធភាព ដើម្បី សម្រេចគោលដៅ ព្រោះវាជាការដឹកនាំមួយដែលឆ្ពោះទៅរកភាពជោគជ័យដូចដែលបានកំណត់ទុកជាមុន។

### ២.១.៤ កម្រិតនៃការគ្រប់គ្រង

- អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ (Top Managers) គឺជាក្បាលម៉ាស៊ីនបញ្ជា និងទទួលខុសត្រូវទូទៅលើរាល់ប្រតិបត្តិការទាំងអស់របស់អង្គភាព អ្នកគ្រប់គ្រងនេះគឺជាអ្នកផ្តួចផ្តើមបង្កើតរូបមន្តយុទ្ធសាស្ត្រក្នុងដំណើរការប្រតិបត្តិការរបស់អង្គភាពគេក៏ត្រូវសំដែងផងដែរនូវភាពជាអ្នកដឹកនាំចាត់តាំងពង្រាង កម្មវិធីធ្វើការងារ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជម្រុញសកម្មភាពការងារឱ្យបានសម្រេចនូវ គោលដៅដែលបានដាក់ចេញ។ ជាទូទៅគេមានឈ្មោះថាៈ ប្រធាន អនុប្រធាន នាយក ឬ នាយករង...។

- អ្នកគ្រប់គ្រងថ្នាក់កណ្តាល (Middle Managers) គឺជាអ្នកដែលទទួលខុសត្រូវផ្ទាល់លើអ្នកគ្រប់គ្រងថ្នាក់ទាប គឺជាអ្នកគ្រប់គ្រងនៅតាមបណ្តា ផ្នែកជំនាញនីមួយៗ ឧទាហរណ៍ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុសំខាន់ជាងនេះទៀត អ្នកគ្រប់គ្រងកណ្តាលជាអ្នកទទួលខុសត្រូវលើការអនុវត្តផែនការ និងគោលនយោបាយតាមផ្នែករបស់អង្គភាព ដើម្បីប្រមូលផ្តុំជាគោលដៅរួមសំដៅសម្រេចផែនការ រួម ។

- អ្នកគ្រប់គ្រងថ្នាក់ទាប (Lowest Managers) គឺជាអ្នកដឹកនាំផ្ទាល់នូវរាល់សកម្មភាពការងាររបស់និយោជិក វាជាជំហ៊ានដំបូងនៃការគ្រប់គ្រងរបស់គេ គឺដឹកនាំសកម្មភាពការងាររបស់និយោជិក ប្រចាំថ្ងៃ ដើម្បីអនុវត្តន៍តាមផែនការដែលបានដាក់ចុះ ដូចនេះអ្នកគ្រប់គ្រងថ្នាក់ទាបត្រូវតែពាក់ព័ន្ធទៅនឹង

ការត្រួតពិនិត្យផ្ទាល់លើការកែតម្រូវ ឬដោះស្រាយរាល់បញ្ហាដែលទាក់ទងទៅនឹងការងារនោះ ប្រការនេះអ្នកគ្រប់គ្រងថ្នាក់ទាបត្រូវមានសមត្ថភាពគ្រប់គ្រាន់ដើម្បីដំណើរការ កាងារ របស់អង្គភាព។ ឧទាហរណ៍ ប្រធានក្រុម ប្រធានផ្នែក ។

## ២.២ ប្រភពចំណូលរបស់ក្រុមហ៊ុន

### ២.២.១ និយមន័យចំណូល

ចំណូល គឺជាការកើនឡើងនៃទ្រព្យសកម្មទោះបានមកពី ប្រភពប្រត្តិបត្តិការអាជីវកម្ម ការផ្តល់មូលនិធិ ឬ បានពីស្ថាប័នណាក៏ដោយ សុទ្ធតែជាចំណូលទាំងអស់។[5]

ចំណូល គឺជាតួលេខសរុបមួយដែលរកបាន ពីការលក់ផលិតផល ឬ សេវាកម្មដែលជាប់ទាក់ទងនឹងប្រតិបត្តិការនៃក្រុមហ៊ុន។ ចំណូលតែងតែត្រូវបានគេសរសេរនៅលើគេ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ចំណូល គឺជាការហូរចូល ឬ ជាការរើកចម្រើននៃទ្រព្យរបស់អង្គភាព។ វាកើតឡើងនៅពេលដែលយើងទទួលសាច់ប្រាក់ពីការទិញ លក់ទំនិញ ឬសេវានានា។

### ២.២.២ ប្រភេទនៃចំណូល

ចំណូលនៅក្នុងអង្គភាពអាចបានមកពីប្រភពជាច្រើន ប៉ុន្តែជាគោលវាមានពីរប្រភេទគឺ៖

- ចំណូលពីការលក់
- ចំណូលពីសេវាកម្ម

ក្រៅពីចំណូលទាំងពីរខាងលើនេះ ប្រទេសកម្ពុជាក៏បានចែងចំណូលថវិកាជាបីប្រភេទបន្ថែមទៀតគឺ៖

**+ ចំណូលសារពើពន្ធ**

ចំណូលសារពើពន្ធ គឺជាពន្ធអាករ និងសិទ្ធិដែលត្រូវបានបង្វែរជាកាតព្វកិច្ចទៅឱ្យរដ្ឋ។ ចំណូលនេះរួមមាន៖ ចំណូលសារពើពន្ធក្នុងប្រទេស និងចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស។[6]

ចំណូលសារពើពន្ធក្នុងស្រុក គឺជាកត់ត្រាចំណូលទទួលបានពីពន្ធដារ និងពន្ធគយក្នុងប្រទេស។ ចំណូលសារពើពន្ធក្នុងស្រុកមានដូចជា៖

ពន្ធផ្ទាល់( ពន្ធលើផលទុន ប្រាក់ចំណេញ )គឺជាចំណូលមកពីការបង់ពន្ធលើផលទុនប្រាក់ចំណេញរបស់រូបវន្តបុគ្គល និងនីតិបុគ្គល។( ថ្នាក់ជាតិ )

ពន្ធលើប្រាក់ចំណេញ( រូបវន្តបុគ្គល )គឺជាចំណូលបានមកពីការបង់ពន្ធលើប្រាក់ចំណេញ របស់សហគ្រាស និងក្រុមហ៊ុន( រូបវន្តបុគ្គល )។( ថ្នាក់ជាតិ )

ពន្ធលើប្រាក់ចំណេញ( នីតិបុគ្គល )គឺជាចំណូលបានមកពីការបង់ពន្ធលើប្រាក់ចំណេញ របស់ សហគ្រាស និងក្រុមហ៊ុន( នីតិបុគ្គល )។( ថ្នាក់ជាតិ )

ពន្ធលើប្រាក់បៀវត្ស គឺជាចំណូលបានមកពីការបង់ពន្ធប្រាក់បៀវត្សដោយបុគ្គលិករដ្ឋ ឬឯកជនដែលជាប់កាតព្វកិច្ចបង់ពន្ធ។( ថ្នាក់ជាតិ )

ពន្ធលើឈ្នួលចលន និងអចលនទ្រព្យ( រូបវន្តបុគ្គល )គឺជាចំណូលមកពីការបង់ពន្ធលើឈ្នួលផ្ទះ ដីធ្លី ផ្ទះសម្បែង និងពីការជួលគ្រឿងយន្ត( រូបវន្តបុគ្គល )។( ថ្នាក់ជាតិ )

5 *វិទ្យាស្ថានវ៉ាន់ដា សៀវភៅ* Intermediate Accounting *ភាគ៣ ( បោះពុម្ពលើកទី១០ )*

6 https://propertyarea.asia/archives/13101 *( 14-01-24 )*

ពន្ធលើឈ្នួលចលន និងអចលនទ្រព្យ(នីតិបុគ្គល)គឺជាចំណូលមកពីការបង់ពន្ធលើឈ្នួលផ្ទះ ដីធ្លី ផ្ទះសម្បែង និងពីការជួលគ្រឿងយន្ត(នីតិបុគ្គល)។(ថ្នាក់ជាតិ)

ពន្ធប្រយោល គឺជាចំណូលទទួលបានពីការបង់អាករលើផលរបរ និងអាករលើតម្លៃបន្ថែម។ អាករនេះអាចត្រូវបានប្រមូលគ្រប់រូបភាពនៃដំណើរផលិតកម្ម ការចែកចាយទំនិញឬសេវា ដែលផលិតនៅក្នុងប្រទេស ឬ នាំចូលពីបរទេស។(ថ្នាក់ជាតិ)

អាករលើផលរបរ គឺជាចំណូលបានមកពីការបង់អាករលើផលរបររបស់ សហគ្រាសនៅក្នុងរបបម៉ៅការ។(ថ្នាក់ជាតិ)

អាករលើតម្លៃបន្ថែម គឺជាចំណូលបានមកពីការបង់អាករបន្ថែមលើតម្លៃទំនិញ ឬសេវាកម្មផ្សេងៗ ដោយសហគ្រាសដែលផលិតទំនិញ ឬចែកចាយទំនិញ និងសេវាកម្មទាំងនោះនៅក្នុងប្រទេស។ (ថ្នាក់ជាតិ) អាករលើតម្លៃបន្ថែម របបនាំចូល(សហគ្រាសប្រេងឥន្ធនៈ)គឺជាចំណូលបានមកពីការបង់អាករបន្ថែម លើតម្លៃប្រេងឥន្ធនៈ ដែលបាននាំចូល។(ថ្នាក់ជាតិ)

អាករលើតម្លៃបន្ថែមរបបនាំចូល(សហគ្រាសផ្សេងទៀតៗ)គឺជាចំណូលបានមកពីការ បង់អាករបន្ថែមលើតម្លៃទំនិញ ឬសេវាកម្មផ្សេងៗ ក្រៅពីប្រេងឥន្ធនៈដែលបាននាំចូល។(ថ្នាក់ជាតិ)

អាករលើតម្លៃបន្ថែម របបនាំចូល ទំនិញជាសម្ភារៈកសិកម្ម(ជាបន្ទុករបស់រដ្ឋ)គឺជាចំណូលបាន មកពីអាករលើតម្លៃបន្ថែមលើការនាំចូលទំនិញជាសម្ភារៈកសិកម្ម(ការកត់ត្រាជាចំណូលថវិកា ក្នុង អនុគណនីនេះ គឺដើម្បីមានតុល្យភាពរវាងចំណាយថវិកាដែលជាបន្ទុករបស់រដ្ឋ)។(ថ្នាក់ជាតិ)

អាករពិសេស គឺជាចំណូលទទួលបានពីការ បង់អាករពិសេសលើទំនិញ និងសេវាមួយចំនួន ដែលបានកំណត់ទាំង របបផ្ទៃក្នុង និងរបបនាំចូល។ អាករពិសេសនេះអាចត្រូវបានប្រមូលតាមកម្រិតណា មួយនៃផលិតកម្ម ឬការចែកចាយ និងត្រូវបានគណនាតាមរយៈតម្លៃ ទំងន់ កម្លាំង ឬគុណភាពនៃផលិតផល ដូចជាពន្ធលើស្ករ បារី ថ្នាំជក់ ស្រា ប្រេងឥន្ធនៈ អាករលើអគ្គិសនី ឬហ្គាស...។ល។(ថ្នាក់ជាតិ ខេត្ត ស្រុក)

អាករពិសេសលើទំនិញមួយចំនួន គឺជាចំណូលបានមកពីការបង់អាករពិសេសលើទំនិញ ដែលផលិត ឬចែកចាយនៅក្នុងប្រទេស។ (ថ្នាក់ជាតិ)

អាករពិសេសលើទំនិញមួយចំនួន របបនាំចូល(សហគ្រាសប្រេងឥន្ធនៈ)គឺជាចំណូលបានមកពីការ បង់អាករពិសេសលើប្រេងឥន្ធនៈដែលបាននាំចូល។(ថ្នាក់ជាតិ)

អាករពិសេសលើទំនិញមួយចំនួន របបនាំចូល(សហគ្រាសផ្សេងៗទៀត)គឺជាចំណូលបានមកពី ការបង់អាករពិសេសលើទំនិញផ្សេងៗទៀត ក្រៅពីប្រេងឥន្ធនៈដែលបាននាំចូលដូចជា អាករពិសេស លើការនាំចូលស្រា បារី...។ល។(ថ្នាក់ជាតិ)

អាករពិសេសលើសេវាមួយចំនួនគឺជាចំណូលបានមកពីការបង់អាករពិសេសលើសេវាមួយចំនួននៅក្នុងប្រទេស។(ថ្នាក់ជាតិ)

អាករសម្រាប់បំភ្លឺសាធារណៈ គឺជាចំណូលទទួលបានមកពីការបង់ពន្ធលើការលក់ស្រាបៀរ និងបារីដែលផលិតមកពីបរទេស និងផលិតផលក្នុងស្រុក នៅក្នុងមណ្ឌលដែនដីរាជធានី-ខេត្ត សម្រាប់ចំណាយការបំភ្លឺសាធារណៈ។(ថ្នាក់ខេត្ត ស្រុក)

អាករលើសេវាដែលបានកំណត់ គឺជាចំណូលទទួលបានពីការបង់អាករលើសេវាដែលបានកំណត់ ដូចជា អាករលើកាស៊ីណូ អាករលើឆ្នោត អាករលើល្បែងភ្នាល់ផ្សេងៗ អាករលើអាកាសយានដ្ឋាន អាករ លើការស្នាក់នៅ និង ពន្ធសត្តឃាត។ អាករនេះត្រូវបានគណនាលើលាភការនៃសេវាពិសេស និងអាករលើល្បែងថែជន្យ ល្បែងភ្នាល់ និងការទទួលបានពីកាស៊ីណូ...។ល។( ថ្នាក់ជាតិ ខេត្ត ស្រុក)

អាករលើកាស៊ីណូគឺជាចំណូលបានមកពីការបង់អាករលើកាស៊ីណូចំណូលពីស្លុតម៉ាស៊ីន។(ថ្នាក់ជាតិ)

អាករលើឆ្នោត គឺជាចំណូលបានមកពីការបង់អាករលើឆ្នោត។ (ថ្នាក់ជាតិ)

អាករលើល្បែងភ្នាល់ផ្សេងៗ គឺជាចំណូលបានមកពីការបង់អាករលើល្បែងភ្នាល់ផ្សេងៗ ដូចជា ការភ្នាល់បាល់...។ល។ (ថ្នាក់ជាតិ)

អាករអាកាសយានដ្ឋាន គឺជាចំណូលបានមកពីការបង់អាករអាកាសយានដ្ឋាន។ (ថ្នាក់ជាតិ)

អាករលើការស្នាក់នៅ គឺជាចំណូលទទួលបានមកពីការបង់អាករលើការស្នាក់នៅតាមសណ្ឋាគារ អាផាតមិន ម៉ូតែល ផ្ទះសំណាក់ និង ប៊ឹងកាឡូ។ (ថ្នាក់ខេត្ត ស្រុក)

ពន្ធសត្តឃាត គឺជាចំណូលបានមកពីការបង់ពន្ធលើការធ្វើអាជីវកម្មពិឃាជសត្វ ដូចជា ជ្រូក គោ ក្របី តាមសត្តឃាតដ្ឋាន។

អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តន៍សកម្មភាព គឺជាចំណូលទទួលបានពីការបង់ អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬការអនុវត្តន៍សកម្មភាព ដូចជា៖ ចំណូលទទួលបានពីការ ផ្តល់ អាជ្ញាប័ណ្ណនាំចេញ និងអាជ្ញាប័ណ្ណធ្វើអាជីវកម្មក្នុងស្រុក ពន្ធប៉ាតង់ និងពន្ធមធ្យោបាយដឹកជញ្ជូន។ (ថ្នាក់ជាតិ ខេត្ត ស្រុក)។

ចំណូលពីអាជ្ញាប័ណ្ណនាំចេញ គឺជាចំណូលបានមកពីការផ្តល់អាជ្ញាប័ណ្ណនាំចេញគ្រប់បែបយ៉ាង។ (ថ្នាក់ជាតិ)

ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក គឺជាចំណូលបានមកពីការផ្តល់អាជ្ញាប័ណ្ណធ្វើអាជីវកម្មក្នុងស្រុក ដូចជាអាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែ អាជ្ញាប័ណ្ណឆ្នោត អាជ្ញាប័ណ្ណទេសចរណ៍...។ អនុគណនីនេះកត់ត្រាផងដែរ នូវពន្ធដែលបង់ដោយអ្នកធ្វើសម្បទានដែលជាអ្នកធ្វើវិនិយោគដោយខ្លួនឯង។(ថ្នាក់ខេត្ត ស្រុក)

ពន្ធប៉ាតង់ គឺជាចំណូលបានមកពីពន្ធប៉ាតង់ចំពោះសហគ្រាសដែលប្រកបអាជីវកម្ម។(ថ្នាក់ខេត្ត ស្រុក)

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ គឺជាចំណូលបានមកពីការបង់ពន្ធមធ្យោបាយដឹកជញ្ជូនដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានយន្ត គ្រប់ប្រភេទដែល ធ្វើចរាចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។(ថ្នាក់ខេត្ត ស្រុក)

ពន្ធប្រថាប់ត្រា គឺជាចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា។ (ថ្នាក់ខេត្ត ស្រុក)

ពន្ធប្រថាប់ត្រា លើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ គឺជាចំណូលបានមក ពីការបង់ពន្ធប្រថាប់ត្រា៤%នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់ ឬ/និងដីធ្លី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។ (ថ្នាក់ខេត្ត ស្រុក)

ពន្ធប្រថាប់ត្រា លើតម្លៃមធ្យោបាយដឹកជញ្ជូន ឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកានកាប់ គឺជាចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា ៤% នៃតម្លៃមធ្យោបាយដឹកជញ្ជូន ឬយានយន្តចំពោះការ ផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ។ (ថ្នាក់ខេត្ត ស្រុក)

ពន្ធប្រថាប់ត្រា លើតម្លៃភាគហ៊ុនចំពោះការផ្ទេរ គឺជាចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា ០,១% នៃភាគហ៊ុនចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។ (ថ្នាក់ខេត្ត ស្រុក)

ពន្ធប្រថាប់ត្រា លើតម្លៃកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា គឺជាចំណូលបានមកពីបង់ពន្ធប្រថាប់ត្រា ០,១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គង់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។ (ថ្នាក់ខេត្ត ស្រុក)

ពន្ធប្រថាប់ត្រា លើលិខិតមានលក្ខណៈគតិយុត្តិ គឺជាចំណូលបានមក ពីការបង់ពន្ធ ប្រថាប់ត្រា ១,០០០,០០០រៀល(មួយលានរៀល) ចំពោះលិខិតមានលក្ខណៈគតិយុត្តិ ជាអាទិ៍លិខិតស្តីពីការ បង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងមានលិខិតស្តីពីការបិទក្រុមហ៊ុន។(ថ្នាក់ខេត្ត ស្រុក)

ពន្ធលើអចលនទ្រព្យ គឺជាចំណូលបានមកពីកា របង់ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបាន ប្រើប្រាស់។(ថ្នាក់ជាតិ)

ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) គឺជាចំណូលបានមកពីការបង់ពន្ធលើអចលនទ្រព្យរួមមានដី ផ្ទះ អាគារ និងសំណង់ផ្សេងៗដែលគ្រប់គ្រងដោយរូបវន្តបុគ្គល។ (ថ្នាក់ខេត្ត ស្រុក)

ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) គឺជាចំណូលបានមកពីការបង់ពន្ធលើអចលនទ្រព្យរួមមានដី ផ្ទះ អាគារ និងសំណង់ផ្សេងៗដែលគ្រប់គ្រងដោយនីតិបុគ្គល។ (ថ្នាក់ខេត្ត ស្រុក)

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺជាចំណូលបានមកពីការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលទុកដីឱ្យនៅទំនេរមិនធ្វើផលិតកម្ម ឬទិញដីទុក។ (ថ្នាក់ខេត្ត ស្រុក)

ចំណូលសារពើពន្ធផ្សេងៗទៀត គឺជាចំណូលទទួលបានពីពន្ធតែមប្រ៍ និង ចំណូលបានមក ពីការពិន័យលើភាពយឺតយ៉ាវ និងកំហុសនៃការបង់ពន្ធ។ (ថ្នាក់ជាតិ)

ពន្ធតែមប្រ៍ គឺជាចំណូលបានមកពីការបង់ពន្ធតែមប្រ៍តាមកិច្ចសន្យា។ (ថ្នាក់ជាតិ)

ការផាកពិន័យ និងទោសបញ្ញត្តិសារពើពន្ធ គឺជាចំណូលបានមកពីការពិន័យលើភាពយឺតយ៉ាវ និងកំហុសនៃការបង់ពន្ធ។(ថ្នាក់ជាតិ)

ចំណូលលក់ឯកសារពន្ធ គឺជាចំណូលពីការលក់ឯកសារពន្ធ។(ថ្នាក់ជាតិ)

ចំណែកឯចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស គឺជាកត់ត្រាចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗលើការនាំចូល និងការនាំចេញ។ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសមានដូចជា៖ ពន្ធនិងអាករលើការនាំចូល គឺជាចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗ លើការនាំចូល។ (ថ្នាក់ជាតិ)

ពន្ធគយពីការនាំចូល គឺជាចំណូលទទួលបានពីការបង់ពន្ធលើការនាំចូលទំនិញផ្សេងៗលើកលែងតែការនាំចូលប្រេងឥន្ធនៈ។ (ថ្នាក់ជាតិ)

កម្រៃពីការងារគយ គឺជាចំណូលទទួលបានពីការយកកម្រៃផ្សេងៗក្នុងការនាំចូល ដូចជាការនាំ ចូលទំនិញសម្រាប់លក់ក្នុងអាគារ លក់ទំនិញរួចពន្ធ ការនាំចូលទំនិញឆ្លងកាត់ ការស្តុកទំនិញក្នុងឃ្លាំង ឬ ទីលានហួសកាលកំណត់ កម្រៃបំពេញបែបបទគយ កម្រៃត្រួតពិនិត្យទំនិញតាមរយៈម៉ាស៊ីនស្កែន និង កម្រៃផ្សេងៗទៀត ដែលពុំមែនជាពន្ធ ឬអាករ។(ថ្នាក់ជាតិ)

ពន្ធគយលើផលិតផលតេលសិលា គឺជាចំណូលទទួលបានពីការបង់ពន្ធលើការនាំចូលប្រេងឥន្ធនៈ។ (ថ្នាក់ជាតិ)

អាករបន្ថែមលើផលិតផលតេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ គឺជាចំណូលទទួលបានពីការ បង់ អាករបន្ថែមចំនួន ០,០២ដុល្លារ ក្នុងមួយលីត្រ ចំពោះការនាំចូលប្រេងសាំង និង០,០៤ដុល្លារ ក្នុងមួយលីត្រ ចំពោះការនាំចូលប្រេងម៉ាស៊ូត ហើយចំណូលនេះ ប្រើប្រាស់សម្រាប់ថែទាំផ្លូវថ្នល់ និង គោលនយោបាយ ជាវាសាស្ត្រ។( ថ្នាក់ជាតិ )

ផលនៃការលក់ផ្នែកគយ គឺជាចំណូលទទួលបានពីការលក់ទំនិញផ្សេងៗ( ល្មើសច្បាប់គយ )ដែលអង្គភាពគយរឹបអូសបាន។ ( ថ្នាក់ជាតិ )

ពិន័យផ្សេងៗលើការនាំចូល គឺជាចំណូលទទួលបានពីការបង់ពិន័យផ្សេងៗលើការនាំចូល។( ថ្នាក់ជាតិ )

ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឪសថ ( ជាបន្ទុករបស់រដ្ឋ ) គឺជាចំណូលបានមក ពីការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឪសថ( ការកត់ត្រាជាចំណូលថវិកាក្នុងអនុគណនីនេះគឺ ដើម្បីមានតុល្យភាពរវាងចំណាយថវិកាដែលជាបន្ទុករបស់រដ្ឋ )។( ថ្នាក់ជាតិ )

ពន្ធនិងអាករលើការនាំចេញ គឺជាចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗ លើការ នាំចេញ។( ថ្នាក់ជាតិ )

អាករលើការនាំចេញឈើ គឺជាចំណូលទទួលបានពីការបង់អាករ លើការនាំចេញឈើគ្រប់ប្រភេទ។ ( ថ្នាក់ជាតិ )

អាករលើការនាំចេញកៅស៊ូ គឺជាចំណូលទទួលបានពីការបង់អាករលើការនាំចេញកៅស៊ូ។( ថ្នាក់ជាតិ )

អាករលើការនាំចេញផលិតផលតេលសិលា គឺជាចំណូលទទួលបានពីការបង់អាករលើការ នាំចេញផលិតផលតេលសិលា។( ថ្នាក់ជាតិ )

អាករលើការនាំចេញទំនិញផ្សេងៗ គឺជាចំណូលទទួលបានពីការបង់អាករលើការនាំចេញទំនិញផ្សេងៗក្រៅពីឈើ កៅស៊ូ និងផលិតផលតេលសិលា។( ថ្នាក់ជាតិ )

កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ គឺជាចំណូលទទួលបានពីការផ្តល់កូតា និងអាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់ ស្បែកជើង ...។ល។( ថ្នាក់ជាតិ )

ពិន័យផ្សេងៗពីការនាំចេញ គឺជាចំណូលទទួលបានពីការពិន័យផ្សេងៗលើការនាំចេញដែល មិនគោរពតាមបទដ្ឋាន។( ថ្នាក់ជាតិ )

ចំណូលមិនមែនសារពើពន្ធ សំដៅដល់ចំណូលដែលទទួលបានមកពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋចំណូលពីសហគ្រាសសាធារណៈភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀតចំណូល ពីសេវាសាធារណៈចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្មវៀរលែងតែការពិន័យនិងការដាក់ទណ្ឌកម្ម ពាក់ព័ន្ធនឹងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត។

## ២.៣ គោលការណ៍ក្នុងការគ្រប់គ្រងចំណូល

### ២.៣.១ និយមន័យគោលការណ៍

គោលការណ៍ គឺជាទ្រឹស្តីដែលចេញប្រើជាគោល សម្រាប់អនុវត្តកិច្ចការឱ្យត្រូវតាមបែបផែនការ ឬជាតម្លៃដែលជាការណែនាំឬការវាយតម្លៃ។នៅក្នុងច្បាប់វាជាច្បាប់មួយដែលត្រូវអនុវត្តតាមធម្មតាត្រូវតែ អនុវត្តតាមដោយខានពុំបាន។ ម្យ៉ាងវិញទៀតគោលការណ៍មានមុខងារពាក់ព័ន្ធពីរនៅក្នុងប្រព័ន្ធច្បាប់។ ដំបូងគោលការណ៍ដើរតួជាកម្លាំងរុញច្រានសម្រាប់ការបង្កើតច្បាប់។ មួយវិញទៀតនោះ គោលការណ៍ មាន សារៈ

សំខាន់ណាស់នៅក្នុងដំណើរការនៃការគ្រប់គ្រងអង្គភាពក្រុមហ៊ុនឬរោងចក្រផងដែរ។ ជាក់ស្តែង នៅក្នុងក្រុមហ៊ុន ឬអង្គភាពមួយដែលបានបង្កើតគោលការណ៍មួយច្បាស់លាស់ គឺតែងតែធ្វើឱ្យក្រុមហ៊ុន ឬអង្គភាពនោះទទួលបានលទ្ធផលមួយដែលគាប់ប្រសើរ ឬ សម្រេចបាននូវគោលដៅដែលបានរំពឹងទុក ផងដែរ។[7]

គោលការណ៍ គឺជាការកំណត់មួយដែលមានលក្ខណៈស្រដៀង នឹងច្បាប់ដែរ ព្រោះគេកំណត់មកក្នុងគោលបំណងយកមកអនុវត្តតាម ដើម្បីបង្កើនភាពងាយស្រួលក្នុងការគ្រប់គ្រង។

**២.៣.២ ប្រវត្តិនៃពាក្យគោលការណ៍**

លោក ម៉ងតេរីយើជាទស្សនវិទូនយោបាយ និងជាអ្នកប្រវត្តិវិទូរបស់បារាំង ដែលត្រូវបានគេស្គាល់ ថាជាស្ថាបនិកសង្គមវិទ្យានិងជាបិតានៃវិទ្យាសាស្ត្រនយោបាយគាត់បានលះបង់ការងាររបស់គាត់ទាំងអស់ ក្នុងឆ្នាំ១៧២៦ ហើយធ្វើការសញ្ជឹងគិត និងធ្វើការទៅក្រៅប្រទេសមានអ៊ីតាលីហុងគ្រីហូឡង់និងប្រទេសអង់គ្លេសជាដើម។ គោលការណ៍(ស្នាដៃ)សំខាន់របស់គាត់គឺការផ្តត់ផ្តង់ច្បាប់ និងការបែងចែកអំណាចក្នុងរដ្ឋ។ លោកបានកំណត់គោលការណ៍មួយចំនួននៅក្នុងស្នាដៃដ៏ល្បីរបស់គាត់ឈ្មោះ The Spirit of Low (1728-1748) ស្នាដៃនេះបានបោះពុម្ពលើកទីមួយក្នុងឆ្នាំ១៧៤៨។ លោក ម៉ងតេរីយើ បានធ្វើការកត់សម្គាល់ថា "មានមនុស្សជាច្រើនដែលដឹកនាំមនុស្សរួមមានអាកាសធាតុ សាសនា ច្បាប់ និងគោលការណ៍ក្នុងអតីតកាលដូចជាសីលធម៌ ទម្លាប់ប្រពៃណី លទ្ធផលទាំងនេះបង្កើតបានជាព្រលឹងទូទៅរបស់ប្រជាជន"។[8]

**២.៣.៣ ការកំណត់គោលការណ៍**

ជាទូទៅគោលការណ៍ត្រូវបានគេកំណត់ជាច្រើនប្រភេទទៅតាមការយល់ឃើញរបស់ បុគ្គលម្នាក់ៗ និងតាមផ្នែកផ្សេងៗជាដើម។ក្នុងនោះផងដែរលោក *Inamori* បានប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ជារៀងរហូតមក នូវគោលការណ៍គ្រប់គ្រងដែលគាត់កំណត់ឡើងដើម្បីឱ្យទទួលបានភាពជោគជ័យសម្រាប់រូបលោកក្នុងពិភពនៃការប្រកួតប្រជែងមុខជំនួញទាំង ១២ ប្រការដូចខាងក្រោម៖

១. បញ្ជាក់ឱ្យបានច្បាស់ពីគោលបំណង និងបេសកកម្មរបស់អ្នកនៅក្នុងការធ្វើជំនួញ។

២. កំណត់នូវគោលដៅប្រកបដោយភាពប្រាកដប្រជា។

៣. រក្សាទុកនូវកម្លាំងដុតបញ្ឆេះជំនក់ចិត្តនៅក្នុងបេះដូងរបស់អ្នកជានិច្ច។

៤. ត្រូវខិតខំប្រឹងប្រែងជាងនរណាៗទាំងអស់។

៥. ចំណូលត្រូវកម្រិតជាអតិបរមា ឯការចំណាយត្រូវកម្រិតជាអប្បបរមា។

៦. ការកំណត់តម្លៃ គឺជាការគ្រប់គ្រង។

៧. ភាពជោគជ័យជាការកំណត់ដោយឆន្ទៈដ៏មោះមុត។

៨. ត្រូវយកដួងវិញ្ញាណជាអ្នកប្រយុទ្ធជាប់នឹងខ្លួន។

៩. ត្រូវប្រឈមមុខនឹងឧបសគ្គលំបាកទាំងឡាយជាមួយភាពក្លាហាន។

១០. មានភាពច្នៃប្រឌិតជានិច្ចជាមួយកិច្ចការងាររបស់អ្នក។

១១. ត្រូវមានទឹកចិត្តល្អ និងប្រកាន់យកភាពស្មោះត្រង់។

7 វិទ្យាស្ថានវ៉ាន់ដារបាយការណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតឈ្មោះសៀប គឹមមាយ ទំព័រទី៨

8 វិទ្យាស្ថានវ៉ាន់ដារបាយការណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតឈ្មោះសៀប គឹមមាយ ទំព័រទី៨

១២. ត្រូវមានភាពសប្បាយរីករាយ និងសុទិដ្ឋិនិយមជានិច្ច។ ដាក់ក្តីសុបិនដ៏អស្ចារ្យ និងក្តីសង្ឃឹមដ៏អស្ចារ្យទាំងឡាយចូលក្នុងជម្រៅបេះដូងនៃភាពបរិសុទ្ធរបស់អ្នក។

## ២.៤ បញ្ហាប្រឈមក្នុងការគ្រប់គ្រងប្រាក់ចំណូល

### ២.៤.១ និយមន័យបញ្ហាប្រឈម

បញ្ហាប្រឈម គឺជាកត្តារាំងស្ទះឬភាពរអាក់រអួលផ្សេងៗដែលតែងតែកើតឡើងក្នុងដំណើរការ អាជីវកម្មទាំងអស់មិនថាក្នុងក្រុមហ៊ុន ឬសហគ្រាសស្វែងរកប្រាក់ចំណូលណាក៏ដោយ ប្រាកដជាជួបនូវ បញ្ហាប្រឈមទាំងនេះដែលបណ្តាលឱ្យក្រុមហ៊ុនមានភាពរាំងស្ទះ និងដំណើរការមិនបានរលូន។[9]

បញ្ហាប្រឈម គឺជាបញ្ហាដែលកើតឡើងហើយប្រឈមនឹងដំណើរការទាំងអស់ក្នុងក្រុមហ៊ុន ជាពិសេសបញ្ហាក្នុងការគ្រប់គ្រង និងបញ្ហាក្នុងដំណើរការខ្សែសង្វាក់ផលិតកម្មជាដើម។[10]

### ២.៤.២ កត្តាដែលធ្វើឱ្យការគ្រប់គ្រងមានបញ្ហា

បញ្ហាប្រឈមខាងលើគឺ បណ្តាលមកពីកត្តាផ្សេងៗមួយចំនួនដូចជា៖

**ក. កត្តាធនធានមនុស្ស**

- អាចបណ្តាលមកពីអ្នកដឹកនាំខ្វះសមត្ថភាពក្នុងការគ្រប់គ្រង ឬការដឹកនាំបុគ្គលិក មិនបានល្អ ដូចជាការមិនបានអនុវត្តទៅតាមផែនការដែលបានរៀបចំទុក និងខ្វះការត្រួតពិនិត្យឡើងវិញ រាល់ការងារ ដែលបានដាក់ឱ្យបុគ្គលិកធ្វើ។

- បុគ្គលិកមួយចំនួនមិនមានទំនួលខុសត្រូវក្នុងការងារ មិនស្របទៅតាមការងារ ដែល អ្នកគ្រប់គ្រងបានចាត់ចែងឱ្យខ្លួនជាដើមហើយបុគ្គលិកមួយចំនួនទៀត គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ដោយមិនខ្វល់ពីក្រុមហ៊ុនដែលជាកត្តា ធ្វើឱ្យក្រុមហ៊ុនខ្វះធនធានបុគ្គលិកដែលសមស្របនឹងការងារ។

-គណនេយ្យករមិនបានអនុវត្តន៍ឱ្យត្រូវតាមស្តង់ដា ឬតាមប្រភេទគណនេយ្យនីមួយៗឱ្យបានច្បាស់លាស់ដែលគណនេយ្យនេះគេបានបែងចែកចេញជាបីគឺ៖

**១. គណនេយ្យហិរញ្ញវត្ថុ (Financial Accounting)**

គណនេយ្យហិរញ្ញវត្ថុគឺជាការផ្តោតការយកចិត្តទុកដាក់ទៅលើការរាយការណ៍ពីសមត្ថភាពអាជីវកម្មទៅកាន់អ្នកខាងក្រៅ ឬអ្នកដែលពុំបានចូលរួមដោយផ្ទាល់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពអាជីវកម្ម។ របាយការណ៍នេះជាទូទៅ គឺជារបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍លំហូរសាច់ប្រាក់ និងរបាយការណ៍ទ្រព្យម្ចាស់។[11]

**២. គណនេយ្យគ្រប់គ្រង (Management Accounting)**

គណនេយ្យគ្រប់គ្រង គឺត្រូវបានផ្តោតសំខាន់ជាមួយនឹងការផ្តល់នូវព័ត៌មានជាសម្ងាត់ សម្រាប់អ្នកប្រើប្រាស់ខាងក្នុងក្រុមហ៊ុនដូចជា អ្នកគ្រប់គ្រងក្រុមហ៊ុន និងប្រធានប្រតិបត្តិការរបស់ក្រុមហ៊ុន ឬអ្នកគ្រប់គ្រងដទៃទៀត។ គណនេយ្យគ្រប់គ្រងអាចផ្ទុយពីគណនេយ្យហិរញ្ញវត្ថុ ពីព្រោះវាបាន ផ្តល់ព័ត៌មានទៅដល់ម្ចាស់បំណុល និងអ្នកប្រើប្រាស់ខាងក្រៅផ្សេងទៀត។[12]

---

9 *វិទ្យាស្ថានវ៉ាន់ដារបាយការណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតឈ្មោះសៀប គឹមមាយ ទំព័រទី១៤*

10 *វិទ្យាស្ថានវ៉ាន់ដារបាយការណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតឈ្មោះសៀប គឹមមាយ ទំព័រទី១៤*

11 *វិទ្យាស្ថានវ៉ាន់ដា សៀវភៅ* Intermediate Accounting *ភាគ៣ ទំព័រទី០២ បោះពុម្ព២០១៩*

12 *វិទ្យាស្ថានវ៉ាន់ដា សៀវភៅ* Intermediate Accounting *ភាគ៣ ទំព័រទី០២ បោះពុម្ព២០១៩*

គណនេយ្យគ្រប់គ្រងវាបានផ្តល់នូវព័ត៌មានដល់អ្នកសម្រេចចិត្តខាងក្នុងក្រុមហ៊ុនក្នុងការសម្រេចគោលដៅប្រាក់ចំណេញរបស់អង្គភាពដូចជាព័ត៌មានអំពីការធ្វើហិរញ្ញប្បទានវិនិយោគនិងសកម្មភាពប្រតិបត្តិការផ្សេងៗ

### ៣. គណនេយ្យពន្ធដារ (Tax Accounting)

គណនេយ្យពន្ធដារគឺជាដំណើរការនៃការរៀបចំនូវចំណូលត្រឡប់ពីការបង់ពន្ធដោយផ្អែកទៅលើមូលដ្ឋានព័ត៌មានគណនេយ្យហិរញ្ញវត្ថុ។ ជាទូទៅគណនេយ្យពន្ធដារ គឺផ្តោតសំខាន់លើ បញ្ហាបង់ពន្ធ រួមទាំងការដាក់លិខិតប្រកាសពន្ធនិងការធ្វើផែនការសម្រាប់ទទួលខុសត្រូវពន្ធដារនាពេលអនាគត។ បើទោះជាយ៉ាងណាក៏ដោយព័ត៌មានគណនេយ្យទាំងនោះគឺ ត្រូវបានគេធ្វើការកត់ត្រា និងធ្វើជារបាយការណ៍ អំពីចំណូលសម្រាប់បង់ពន្ធ។[13]

**ខ. កត្តាបច្ចេកទេស**

- បណ្តាលមកពីការរៀបចំប្រព័ន្ធការងារតាមប្រព័ន្ធអេឡិចត្រូនិកមិនបានត្រឹមត្រូវ

-ការកំណត់ប្រព័ន្ធគ្រប់គ្រងចំណូលតាមកុំព្យូទ័រ នៅមានភាពខ្វះខាតចន្លោះដោយពេលខ្វះនៅមានការខុសឆ្គង

កត្តាទាំងពីរចំណុចខាងលើនេះហើយដែលជាបញ្ហាប្រឈមក្នុងក្រុមហ៊ុនដែលធ្វើឱ្យក្រុមហ៊ុនជួបប្រទះភាពរាំងស្ទះក្នុងដំណើរការអាជីវកម្ម ហើយក៏អាចបណ្តាលឱ្យខាតបង់ទ្រព្យសម្បត្តិ និងខាតពេលវេលាជាដើម។ ម្យ៉ាងទៀតការគ្រប់គ្រងចំណូល គឺជាកត្តាសំខាន់ហើយបើយើងមិនមានការគ្រប់គ្រងបានច្បាស់លាស់ទេវាធ្វើឱ្យក្រុមហ៊ុនខ្វះដើមទុន អាចដួលរលំបាន។

ដូច្នេះហើយមិនថាម្ចាស់ក្រុមហ៊ុនឬអ្នកគ្រប់គ្រងទេត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ចំពោះបញ្ហាទាំងនេះចៀសវាងការជួបប្រទះវិបត្តិផ្សេងៗក្នុងក្រុមហ៊ុន។

13 *វិទ្យាស្ថានវ៉ាន់ដារបាយការណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតឈ្មោះសៀប គឹមមាយ ទំព័រទី១៥*

# ជំពូកទី៣
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៣

# ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ

## ៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនស្រាបៀរអង្គរ

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុនស្រាបៀរអង្គរ

**"ស្រាបៀរ អង្គរ"** ត្រូវបានផលិតចេញជាលើកដំបូងនៅឆ្នាំ១៩៦៣។ រោងចក្រនេះត្រូវបាន បង្កើត ឡើងដោយរដ្ឋាភិបាលកម្ពុជានាដើមទសវត្សទី៦០ដែលបានកសាងនិងផ្តល់ជំនួយការបច្ចេកទេសដោយជនជាតិ បារាំង (គម្រោងបង្កើតរោងចក្រស្រាបៀរនេះមានតាំងពីដើមទសវត្សទី២០ក្នុងអំឡុងសម័យអាណានិគមបារាំង មកម្ល៉េះ) ។ រោងចក្រនេះ បានផលិតស្រាបៀរដោយដាក់ស្លាកសញ្ញាពីរគឺ ស្រាបៀរអង្គរ និងស្រាបៀរបាយ័ន។

នៅទសវត្ស៧០(អំឡុងសម័យ លន់ នុល)រោងចក្របានខាតបង់ប្រាក់ជាបន្តបន្ទាប់ ហើយចុងក្រោយត្រូវបានបិទនិងបំផ្លាញដោយរបបខ្មែរក្រហម។ ដូច្នេះមិនមានផលិតផលស្រាបៀរនៅ ចុងទសវត្សទី៧០ និងទសវត្សទី៨០ ទៀតទេ។




*១.១ LOGO របស់ស្រាបៀរអង្គរ*

រូបសញ្ញានៅលើស្រាបៀរអង្គរដោយខេមប្រ៊ូវគឺមានកំពូលប្រាសាទអង្គរប្រាំគឺដូចនឹងរូបតំណាងនៅលើទង់ជាតិនៅសម័យនោះដែរ(សម័យរដ្ឋកម្ពុជា)។បន្តិចក្រោយមកនៅឆ្នាំ១៩៩២ក្រោយការរៀបចំការបោះឆ្នោតរបស់UN(សម័យអ៊ុនតាក់)ទង់ជាតិថ្មីត្រូវបានបង្កើតឡើងសម្រាប់ព្រះរាជាណាចក្រកម្ពុជាដែលមានរូបតំណាងជាប្រាសាទអង្គរកំពូលបីវិញ ដូច្នេះក្រុមហ៊ុនក៏បានកែច្នៃរូបសញ្ញា ឱ្យមានកំពូលប្រាសាទបីវិញដែរ។ នៅក្នុងឆ្នាំ១៩៩១ក្រុមហ៊ុនមកពីប្រទេសអូស្ត្រាលីបានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការបង្កើតឡើងវិញនូវរោងចក្រស្រាបៀរអង្គរ ប៉ុន្តែត្រូវដកទៅវិញដោយសារស្ថានភាព មិននឹងនរនៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មកនៅក្នុងឆ្នាំនោះដែរក្រុមហ៊ុនមកពីប្រទេសម៉ាឡេស៊ីបានទិញក្រុមហ៊ុននិងប្តូរឈ្មោះទៅជា"ខេមប្រ៊ូវ (Cambrew)"។នៅឆ្នាំ១៩៩២ចង្វាក់ផលិតកម្មស្រាបៀរអង្គរក៏បានចាប់ផ្តើមឡើងវិញនៅទីតាំងដើមគឺនៅទីក្រុងព្រះសីហនុ។ ផលិតផលស្រាបៀរអង្គរ មិនត្រឹមតែពេញនិយមនៅក្នុង ប្រទេសកម្ពុជាទេពួកវាក៏ត្រូវបាននាំចេញទៅប្រទេសជាច្រើនជុំវិញពិភពលោករួមមាន សហភាពអឺរ៉ុប ជប៉ុន អូស្ត្រាលី និង សហរដ្ឋអាមេរិកជាដើម។

### ក. ទីតាំងរបស់ក្រុមហ៊ុនស្រាបៀរអង្គរ

ក្រុមហ៊ុនស្រាបៀរអង្គរ មានអាស័យដ្ឋានស្ថិតនៅតាមបណ្តាផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ទល់មុខនឹងក្រុមហ៊ុនអាកាសចរណ៍ ខេមប៊ូឌា អ៊ែរ ខេថឺរីង សឺវ៉ិស អោលធីឌី។ ក្រុមហ៊ុននេះមាន លោកបណ្ឌិតសែរបាយការណ៍ស្រាវជ្រាវ ថងខាំច័ន្ទជាអគ្គនាយកប្រតិបត្តិ ក្រុមហ៊ុន។




*១.២ រូបភាពក្រុមហ៊ុនស្រាបៀរអង្គរ*

### ៣.១.២ គោលនយោបាយក្រុមហ៊ុនស្រាបៀរអង្គរ

Angkor Premium Beer គឺជាម៉ាកស្រាបៀរមួយដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅប្រទេសកម្ពុជា ដែលត្រូវបានគេស្គាល់តាមរយៈរសជាតិឈ្ងុយឆ្ងាញ់ និងគុណភាពខ្ពស់។ រសជាតិដ៏ឈ្ងុយឆ្ងាញ់នេះ គឺដោយសារ ស្រាបៀរអង្គរត្រូវបានផលិត ឡើងដោយប្រើប្រាស់ប្រភពទឹកដែលល្អជាងគេនៅក្នុងប្រទេស គឺជាទឹក ច្រោះបរិសុទ្ធតាមភ្នំ។ចំនួន៩០ភាគរយនៃគ្រឿងផ្សំស្រាបៀរអង្គរគឺទឹកដូច្នេះវាសំខាន់ណាស់ដែលត្រូវប្រើ ប្រាស់ទឹកដែលមានគុណភាពល្អបំផុត ដើម្បីផលិតស្រាបៀរឱ្យមានគុណភាពល្អជាងគេ។

ស្រាបៀរអង្គរផ្តោតសំខាន់ទៅលើគុណភាព ជាជាងការផលិតស្រាបៀរ ដែលគ្រាន់តែដើម្បី រកប្រាក់ចំណេញ។ ក្រុមហ៊ុនផលិតស្រាបៀរជាច្រើន បានផ្អាប់ស្រាបៀររបស់ត្រឹមតែរយៈពេល ៧ថ្ងៃតែ ប៉ុណ្ណោះ មុននឹងចាប់ផ្តើមដាក់លក់ ប៉ុន្តែក្រុមហ៊ុនស្រាបៀរអង្គរ គឺផ្អាប់ទុកស្រាបៀររយៈពេល ៧ថ្ងៃ ហើយរក្សាទុករយៈពេល១៤ថ្ងៃទៀត ដើម្បីធ្វើឱ្យវាមានរសជាតិកាន់តែឈ្ងុយឆ្ងាញ់ សម្រាប់អ្នកពិសា។ បើទោះបីជាមានការនាំចេញមួយចំនួនតូចទៅប្រទេសផ្សេងៗក៏ដោយប៉ុន្តែ ក្រុមហ៊ុនស្រាបៀរអង្គរ គឺផ្តោតសំខាន់ដើម្បីបម្រើប្រជាជនកម្ពុជា ដោយស្រាបៀរនេះគឺជាស្រាបៀរជាតិ។

លោក Michael បានឱ្យដឹងថាស្រាបៀរអង្គរ ជាផ្នែកមួយនៃមោទនភាពរបស់អតិថិជនកម្ពុជា ចំពោះគុណតម្លៃ និងវប្បធម៌របស់ខ្មែរ។ ការអភិវឌ្ឍស្រាបៀរអង្គរថ្មី គឺជាកិច្ចខិតខំប្រឹងប្រែងចុងក្រោយបង្អស់ ដែលបានគូសបញ្ជាក់តាម រយៈម៉ាកសញ្ញាផលិតផល ដែលបានបញ្ជាក់អំពីទីតាំងប្រទេសកម្ពុជា និង ប្រជាជនកម្ពុជា។ ការខិតខំប្រឹងប្រែងមួយនេះ ផលិតផលស្រាបៀរអង្គរ ត្រូវបានចាត់ចូលនៅក្នុងចំណោមផលិតផល ជាយុទ្ធសាស្ត្រសំខាន់ៗ និងជាអាទិភាពផងដែរ។ នេះជាចំណាប់អារម្មណ៍បន្ថែមរបស់លោក Matteo។

ក្រុមហ៊ុនស្រាបៀរអង្គរក៏បានរៀបចំគោលនយោបាយមួយចំនួន ដើម្បីឱ្យក្រុមហ៊ុនអាចដំណើរការបានយ៉ាងរលូន មានភាពរីកចម្រើន និងមាននិរន្តរភាពមានដូចជា៖

-គុណភាពនៃផលិតផល( ជាស្រាបៀរដែលមានគុណភាពខ្ពស់ មានអនាម័យល្អផលិតតាមស្តង់ដាគុណភាព)

-ផ្តល់សេវាជូនអតិថិជនឱ្យបានទាន់ចិត្ត

-ផ្គត់ផ្គង់ផលិតផលឱ្យបានគ្រប់គ្រាន់ ជូនដល់អតិថិជនតាមតម្រូវការ

-និយោជិតត្រូវមានភាពស្មោះត្រង់ អត់ធ្មត់នឹងការងារ មិនកេងប្រវ័ញ្ច

-មានអាកប្បកិរិយា និងទំនាក់ទំនងល្អ

-ត្រូវគោរពពេលវេលា...។

❖ បែបបទក្នុងការអនុវត្តការងារ និងរក្សាសណ្តាប់ធ្នាប់ឱ្យបានល្អ

-ត្រូវគោរពតាមការចាត់តាំងការងារ ដែលប្រធានផ្នែកបានដាក់ឱ្យធ្វើ

-ត្រូវរក្សាសណ្តាប់ធ្នាប់ឱ្យបានល្អក្នុងម៉ោងធ្វើការ

-ហាមបង្ករចលាចលដែលបង្កឱ្យប៉ះពាល់ដល់ការងារ និងអ្នកដទៃ

-មិនត្រូវឃោសនា ឬនិយាយអ្វីដែលមិនពិតពីក្រុមហ៊ុន

-មិនត្រូវលេងល្បែងស៊ីសងនៅក្នុងបរិវេណក្រុមហ៊ុន

-មិនត្រូវគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ត្រូវគិតពីប្រយោជន៍រួមជាធំ

-ត្រូវចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន...។

**៣.១.៣ បេសកកម្ម និងទស្សនៈវិស័យ**

ដើម្បីបញ្ជាក់ពីគុណភាពរបស់ក្រុមហ៊ុនស្រាបៀរអង្គរ ស្រាបៀរនេះបាន ឈ្នះមេដាយមាស ជា រោងចក្រផលិតស្រាបៀរល្អក្នុងឆ្នាំ២០១៦ ពីការជ្រើសរើសរបស់Monde Selectionដែលជា វិទ្យាស្ថាន គុណភាពអន្តរជាតិនៅទីក្រុង Brussels នៃប្រទេសបេលហ្សិក ដែលជាទីតាំងផលិតស្រាបៀរ មានគុណភាព ខ្ពស់។ ស្រាបៀរអង្គរ ក៏បានឈ្នះមេដាយកាលពីឆ្នាំ២០១៣ និង ឆ្នាំ២០១៥ ផង ដែរ។ វាបញ្ជាក់ឱ្យឃើញ ពីការជោគជ័យនៃផលិតផលកម្ពុជា នៅក្នុងទីផ្សារអន្តរជាតិ ក៏ដូចជាការបង្ហាញឱ្យឃើញពីគុណភាពនៃ គ្រឿងផ្សំ និង ការតាំងចិត្តផលិតស្រាបៀរដែលមានគុណភាពល្អលើសគេ។

**ក. បេសកកម្ម**

ការកំណត់ពីបេសកកម្ម គោលដៅ ចក្ខុវស័យ ជាកត្តាមួយយ៉ាងសំខាន់ដែលក្រុមហ៊ុន មិនត្រូវមើល រំលងព្រោះវា ជាបញ្ហាផ្ទៃក្នុងដែលត្រូវកំណត់ដើម្បីជាវិធានការក្នុង ការសម្រេចបាននូវភាពជោគជ័យ ក្នុងក្រុមហ៊ុន។

គោលដៅរបស់ក្រុមហ៊ុនស្រាបៀរអង្គរគឺចង់ឱ្យអាជីវកម្មរបស់ខ្លួនមានភាពរីកចម្រើនប្រកបដោយនិរន្តរភាព និងមានភាពឈានមុខគេក្នុងទីផ្សារទូទាំងពិភពលោក។

ខាងក្រោមនេះ គឺជាកត្តាមួយចំនួនដែលក្រុមហ៊ុនបាននឹងកំពុងអនុវត្តន៍ និងកំពុងតែពង្រឹង ដំណើរការ៖

-ពន្លឿនកំណើនផលិតផលឱ្យដល់កម្រិតកំពូល ស្របតាមតម្រូវការ

-ធ្វើឱ្យក្លាយជាក្រុមហ៊ុនផលិតស្រាបៀរមួយដែលដំណើរការបានយ៉ាងល្អបំផុត រួមទាំងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុផងដែរ

-រួមចំណែកជាមួយភាពរីកចម្រើននៃវប្បធម៌ពិភពលោកដោយខិតខំកែលម្អសង្គមឱ្យកាន់តែប្រសើរឡើងតាមរយៈផលិតផលដែលយើងបានផលិត និងលក់

-បង្កើនប្រសិទ្ធភាពផលិតផល និងកាត់បន្ថយថ្លៃដើម(បើអាចធ្វើបាន)

-ពន្លឿនដល់ការអនុវត្តការងារ គឺធ្វើឱ្យការផលិតបានលឿនជាងមុន ដើម្បីកុំឱ្យខាតពេលវេលាច្រើន

-រក្សាជំហរទីផ្សារក្នុងការលក់ចេញ

-ប្រសិទ្ធភាពក្នុងការគ្រប់គ្រងផ្នែកទាំងអស់ក្នុងក្រុមហ៊ុន

-ធ្វើការផ្សព្វផ្សាយពីផលិតផលរបស់ខ្លួន ដើម្បីឱ្យគេទទួលស្គាល់បានកាន់តែច្រើន...។

លើសពីនេះ ក្រុមហ៊ុនបានរិះរកមធ្យោបាយផ្សេងៗទៀតដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីអតិថិជនដូចជាការបង្កើតរូបរាងថ្មីរបស់ស្រាបៀរអង្គរដែលគួរឱ្យទាក់ទាញជាងមុន និងការធ្វើយុទ្ធសាស្ត្រទីផ្សារជាដើម។

## ១. រូបរាងថ្មីរបស់ស្រាបៀរអង្គរ

កាលពីពេលថ្មីៗនេះក្រុមហ៊ុនCarlsbergបានបង្កើនភាគហ៊ុនរបស់ខ្លួនបន្ថែមនៅក្នុងក្រុមហ៊ុន ខេមប្រ៊ូវពី៥០ ភាគរយទៅដល់ ៧៥ ភាគរយ។ គំនិតផ្តួចផ្តើមបង្កើត ស្រាបៀរអង្គររូបរាងថ្មីនេះគឺ គ្រាន់តែជាជំហានដំបូងនៅក្នុងដំណោមយុទ្ធសាស្ត្រទីផ្សារជាច្រើនប៉ុណ្ណោះ។

ពិធីបង្ហាញរូបរាងស្រាបៀរអង្គរថ្មីជាផ្លូវការ បានធ្វើឡើងនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩។ អតិថិជនមានឱកាសចូលរួមធ្វើការសាកល្បងផលិតផលដែលខ្លួនចូលចិត្តនៅតាមហាងមួយចំនួននិងតាមរយៈកម្មវិធីអនឡាញជាមួយគ្នានេះផងដែរ អតិថិជនក៏អាចមានឱកាសឈ្នះរង្វាន់ជាសាច់ប្រាក់ផលដែរ ដើម្បីបង្កើនបទពិសោធន៍ និងភាពរីករាយរបស់ពួកគេទ្វេដង។

រូបរាងថ្មីនៃស្រាបៀរអង្គរថ្មី ដែលត្រូវបានផ្សព្វផ្សាយចេញកាលពីឆ្នាំមុន ក៏មានលក្ខណៈទាក់ទាញដែរ។ ក្រុមហ៊ុនបានហៅឡូហ្គោរង្វង់នេះថា “ខ្សែរង្វង់នៃជីវិត” ដោយបង្ហាពីសារៈសំខាន់ នៃការធ្វើអំពើល្អមួយ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ គោលកំនិតនៃការ “បន្តការធ្វើអំពើល្អ”នេះ គឺជាគោលគំនិតមួយដែល សំខាន់ ក្នុងវប្បធម៌ខ្មែរ ហើយត្រូវបានគេចាត់ទុកថា មិនមានពេលបញ្ចប់ទេ។ ពណ៌មាសនៃរង្វង់នេះតំណាងឱ្យ ទ្រព្យសម្បត្តិ និងភាពរុងរឿងដល់ប្រជាជនទាំងអស់។




១.៣ រូបរាងថ្មីរបស់ស្រាបៀរអង្គរ

ស្រាបៀរអង្គរថ្មី ត្រូវបានប្រើប្រាស់នូវ វត្ថុធាតុដើមដ៏ល្អបំផុត មានប្រភពមកពីទីកន្លែង នៃបណ្តាញរបស់ក្រុមហ៊ុន Carlsberg Group ដើម្បីផលិតស្រាបៀរ ដែលប្រកបដោយទេពកោសល្យខ្ពស់ នៅក្នុងប្រវត្តិនៃការផលិតស្រាបៀរ របស់ក្រុមហ៊ុន Carlsberg កាលពីជាង១៧០ឆ្នាំមុន។ ដោយឡែកស្រាបៀរ ត្រូវបាន ផលិតចេញពីប្រទេស ដែលមានបទពិសោធន៍ក្នុងការផលិតស្រាបៀរ និងមានរោងចក្រផលិតស្រាបៀរធំ ជាងគេ នៅក្នុងតំបន់អាស៊ី អាគ្នេយ៍ ហើយដំណើរការនៃការផលិតស្រាបៀរ ស្របតាមស្តង់ដា និង បច្ចេកវិទ្យាទំនើបចុងក្រោយបង្អស់មកពីអឺរ៉ុប។

វាជាម៉ាកសញ្ញាដ៏ពេញនិយមរបស់អតិថិជនជាច្រើននៅតាមតំបន់នានាក្នុងពិភពលោកផងដែរដូចជា នៅសហរដ្ឋអាមេរិក អូស្ត្រាលី ចិន ហុងកុង ថៃ កូរ៉េខាងត្បូង ជប៉ុន បារាំង និងនូវែលសេឡង់។ យើង ជឿជាក់ថានេះជាអ្វីដែលប្រជាជនកម្ពុជាមានមោទនភាព។

ស្រាបៀរអង្គររូបរាងថ្មីនេះត្រូវបានផលិតឡើងដោយផ្អែកលើគោលការណ៍របស់ Carlsberg Operating Manual (COM) និងប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាទំនើបដូចជា Lean, TPM, 5S ជាដើម។

ក្រុមហ៊ុនខេមប្រ៊ូវចាប់ផ្តើមនាំចេញស្រាបៀរអង្គររូបរាងថ្មីរបស់ខ្លួន ហើយក្រុមហ៊ុនផលិតក្នុងស្រុកមកពីឧស្សាហកម្មផ្សេងៗក៏នាំចេញផលិតផលរបស់ពួកគេផងដែរដើម្បីបង្កើនសកម្មភាពពាណិជ្ជកម្ម និងជំរុញសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

☞ ស្រាបៀរអង្គរត្រូវបានគេផលិតឡើងដោយមានគ្រឿងផ្សំដូចខាងក្រោម៖

ស្រាបៀរអង្គរ ជាផលិតផលរបស់ប្រទេសកម្ពុជា យ៉ាងណាក្តីវា ផ្សំមកពីគ្រឿងផ្សំដែលមាន គុណភាពខ្ពស់ ដែលយកមកពីបណ្តាប្រទេសផ្សេងៗ ដូចជាប្រទេសបារាំង សហរដ្ឋអាមេរិក អូស្ត្រាលី និងដាណឺម៉ាកដើម្បីជានារសជាតិល្អនៃស្រាបៀរនេះ។ សមាសធាតុសំខាន់ក្នុងការផលិតស្រាបៀរនេះ រួមមាន៖

- ទឹក៖ ជាប្រភពទឹកដែលស្អាត មានស្តង់ដាក្នុងការផលិត

- ស្រូវសាលីៈ ស្រូវសាលីមានសារជាតុយ៉ាងច្រើនដូចជាប្រូតេអ៊ីន Mineral វីតាមីន និងសារជាតុចិញ្ចឹមមួយចំនួនទៀត
- ផ្ការុក្ខជាតិ Hopsៈ គេយកផ្កាញីដើម្បីផលិតបានជារសជាតិ ហើយគេយកផ្កាទាំងមូលផលិតជា Aroma (ផលិតជាក្លិន)
- យីស(Yeast)ៈ ត្រូវរក្សាទុកនៅសីតុណ្ហភាពទាប (ប្រហែលបីអង្សារ) ដើម្បីកុំឱ្យខូចគុណភាព

## ២. យុទ្ធសាស្ត្រទីផ្សារ

លោក Jensen ដែលជានាយកគ្រប់គ្រងទូទៅ បានថ្លែងថាៈ "ក្រុមផ្នែកលក់របស់យើង បានបង្កើនយុទ្ធនាការទីផ្សារតាមរយៈ Market Impact Team (MIT) កំពុងប្រព្រឹត្តទៅនៅតាមបណ្ដាខេត្ត ក្រុងធំៗ មួយចំនួនដូចជារាជធានីភ្នំពេញ ខេត្តកណ្ដាល សៀមរាប បាត់ដំបង និងខេត្តព្រះសីហនុដើម្បីបង្កើន និងជានាសេវាកម្មដល់អតិថិជន" ។

លោកបានសង្កត់ធ្ងន់ថាការផ្ដោតអារម្មណ៍របស់ក្រុមហ៊ុនខេមប្រ៊ូវនាពេលបច្ចុប្បន្នគឺ ដើម្បីជានានូវការណែនាំស្រាបៀរអង្គររូបរាងថ្មីនេះប្រកបដោយវដ្ដជីវៈ និងដើម្បី ទទួលបាន ជោគជ័យ ពេញលេញ។

លោកជឿជាក់ថាការធ្វើបែបនេះនឹងជួយបញ្ជាក់ទីតាំងរបស់ស្រាបៀរអង្គរ ថាជាស្រាបៀរឈានមុខគេនៅកម្ពុជា និងជួយបញ្ជាក់តំណែងរបស់ក្រុមហ៊ុនខេមប្រ៊ូវថាជាក្រុមហ៊ុនផលិតស្រាបៀរឈានមុខគេនៅក្នុងប្រទេស។

លោកបន្តថាៈ "ក្រុមខ្សែចង្វាក់ផ្គត់ផ្គង់រួមរបស់យើងគឺមានសមត្ថភាពក្នុងការគាំទ្រដល់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព នៅក្នុងខ្សែចង្វាក់ដ៏មានតម្លៃរបស់យើងរួមទាំងការធានានូវគុណភាពស្រាបៀរល្អឥតខ្ចោះ ក្នុងអំឡុងពេលនៃដំណើរការដឹកជញ្ជូនផងដែរ"។



*១.៤ រូបភាពក្នុងរោងចក្រស្រាបៀរអង្គរ*

## ៣. ទស្សនវិស័យ

ក្រុមហ៊ុនស្រាបៀរអង្គរ ជាក្រុមហ៊ុនមួយដែលមានភាពល្បីល្បាញទូទាំងប្រទេស ដោយសារក្រុមហ៊ុននេះជាប្រភេទក្រុមហ៊ុនមួយដែលមានស្តង់ដាច្បាស់លាស់ក្នុងការផលិត ហើយបានធ្វើឱ្យអតិថិជនមានការ

ពេញចិត្តចំពោះគុណភាពរបស់ស្រាបៀរនេះ។ ហើយក្រុមហ៊ុនក៏បានកំណត់នូវទស្សនវិស័យមួយចំនួន ផង ដែរក្នុងក្រុមហ៊ុនដូចខាងក្រោម៖

- គោលបំណងដ៏ធំបំផុតរបស់ក្រុមហ៊ុនស្រាបៀរអង្គរគឺធ្វើយ៉ាងណាឱ្យមានការគាំទ្រច្រើនពីសំណាក់អតិថិជន ហើយធ្វើឱ្យអតិថិជនមានការពេញចិត្តទាំងគុណភាព ទាំងសេវាកម្ម និងតម្លៃ
- ក្រុមហ៊ុនក៏បានខិតខំប្រឹងប្រែងពង្រឹងការផលិតរបស់ខ្លួនឱ្យបានល្អដើម្បីឈានទៅដល់ទីផ្សារអន្តរជាតិឱ្យកាន់តែច្រើនឡើងទ្វេដង។
- មិនត្រឹមតែប៉ុណ្ណោះក្រុមហ៊ុនបានរៀបចំគម្រោងក្នុងការពង្រីកសាខាឱ្យបានកាន់តែច្រើន ទាំងក្នុងស្រុក និងក្រៅស្រុក ដើម្បីបំពេញតម្រូវការអតិថិជន និងដើម្បីឱ្យកាន់តែមានភាពល្បីល្បាញ។

## ៣.២ ប្រភពចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ

ស្រាបៀរអង្គរ គឺជាស្រាបៀរដែលទទួលបានពានរង្វាន់ជាច្រើនក្នុងការប្រកួតលំដាប់អន្តរជាតិរួម ទាំងការទទួលបាននូវមេដាយមាសបន្ថែមទៀតនាពេលថ្មីៗនេះពីស្ថាប័នត្រួតពិនិត្យនិងវាយតម្លៃ គុណភាព ស្រាបៀរលំដាប់អន្តរជាតិ( ម៉ុងដ៍សេឡិកសិន )។ ដោយសារតែផលិតផលរបស់ក្រុមហ៊ុនជាផលិតផល ដែលមានគុណភាពមានស្តង់ដាអនាម័យខ្ពស់ ជាហេតុធ្វើឱ្យក្រុមហ៊ុនមិនពិបាកក្នុងការស្វែងរកប្រាក់ ចំណូលនោះឡើយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ក្រុមហ៊ុន នៅតែបន្តស្វះស្វែងរកប្រាក់ចំណូល ឱ្យបានកាន់តែច្រើនឡើងផងដែរតាមដែលអាចធ្វើបាន។

➢ ប្រភពប្រាក់ចំណូលដ៏ធំបំផុតរបស់ក្រុមហ៊ុនគឺ បានមកតាមរយៈការលក់ផលិតផលសម្រេច ជូនអតិថិជនគឺស្រាបៀរអង្គរនេះតែម្តង។ ហើយការលក់នេះគឺមានលក់ជាបោះដុំ និងលក់រាយទៅតាម ដេប៉ូផ្សេងៗតាមដែលអតិថិជនបានកម្ម៉ង់។

ដោយសារតែការលក់ផលិតផលរបស់ក្រុមហ៊ុនអាចរកចំណូលបាននៅមានកម្រិត ទើបក្រុមហ៊ុន ខិតខំស្វែងរកវិធីសាស្ត្រផ្សេងៗធ្វើយ៉ាងណាឱ្យអតិថិជនមាការពេញចិត្ត និងគាំទ្រឱ្យបានកាន់តែច្រើន។ ហើយក្រុមហ៊ុនក៏បានសម្រេចយកនូវវិធីសាស្ត្រមួយចំនួនយកមកអនុវត្តន៍ និងដើម្បីពង្រឹងដល់ការស្វែងរកចំណូលរបស់ខ្លួនមានដូចជា៖

- ពង្រឹងប្រព័ន្ធផ្សព្វផ្សាយ៖គឺធ្វើយ៉ាងណាឱ្យការផ្សព្វផ្សាយកាន់តែមានភាពទូលំទូលាយមិនថាតាមរយៈទូរទស្សន៍ វិទ្យុ Facebook, Website ឬជាផ្ទាំងប៉ាន់ណូផ្សេងៗជាដើម។ ការធ្វើបែបនេះ គឺដើម្បីឱ្យអតិថិជនបានដឹងកាន់តែច្រើនពីផលិតផលរបស់ខ្លួន
- កម្មវិធីប្រគុំតន្ត្រី៖ គឺដើម្បីឱ្យមានអ្នកចូលរួមទស្សនាហើយបានដឹងពីរស់ជាតិនៃផលិតផល ក្នុងគោលបំណងដើម្បីស្វែងរកចំណូលឱ្យបានច្រើន
- កម្មវិធី Promotion៖ ក្រុមហ៊ុនបានប្រើវិធីសាស្ត្រទាក់ទាញចំណាប់អារម្មណ៍ពីអតិថិជនដោយដាក់ជារង្វាន់ក្នុងក្រវិលកំប៉ុងមានដូចជា រង្វាន់ស្រាបៀរ លុយសុទ្ធ ម៉ូតូ និងរង្វាន់ផ្សេងៗទៀតជាច្រើន។ ការធ្វើបែបនេះគឺ ក្រុមហ៊ុនកាន់តែទទួលបានការគាំទ្រទ្វេឡើងដែលធ្វើឱ្យចំណូលក៏កាន់តែកើនឡើង។

## ៣.៣ គោលការណ៍គ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ

គ្រប់ក្រុមហ៊ុនទាំងអស់មិនថាក្រុមហ៊ុនណាក៏ដូចជាក្រុមហ៊ុនណាដែរម្ចាស់ក្រុមហ៊ុនតែងតែមានការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងផ្នែកទាំងអស់នៅក្នុងក្រុមហ៊ុនដើម្បីឱ្យក្រុមហ៊ុនដំណើរការបានល្អ និងដើម្បីកាត់បន្ថយបញ្ហាផ្សេងៗដែលកើនឡើងជាពិសេសគឺការគ្រប់គ្រងប្រាក់ចំណូលឱ្យបានល្អដើម្បីកុំឱ្យក្រុមហ៊ុនមានការខាតបង់ទ្រព្យសម្បត្តិ ឬសម្ភារៈអ្វីមួយ ដែលជាហេតុនាំឱ្យក្រុមហ៊ុនអាចដួលរលំបាន។ ការគ្រប់គ្រងនេះគឺមានសារៈសំខាន់ណាស់ហេតុនេះហើយយើងត្រូវយកចិត្តទុកដាក់ឱ្យបានខ្ពស់ចៀសវាង ហានិភ័យណាមួយដែលកើតឡើងដោយចេតនាក្តី ឬអចេតនាក្តី។ ក្នុងនោះផងដែរក្រុមហ៊ុនស្រាបៀរអង្គរ ក៏បានខិតខំព្យាយាមយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងប្រាក់ចំណូលរបស់ខ្លួនផងដែរដោយក្រុមហ៊ុនបាន កំណត់នូវគោលការណ៍មួយចំនួនឡើងដើម្បីយកមកអនុវត្តន៍ក្នុងក្រុមហ៊ុន។

**៣.៣.១ វិធីសាស្ត្រក្នុងការគ្រប់គ្រងចំណូល**

ក្រុមហ៊ុនបានកំណត់វិធីសាស្ត្រមួយចំនួនក្នុងការគ្រប់គ្រងចំណូលដើម្បីឱ្យមានប្រសិទ្ធភាពមានដូចខាងក្រោម៖

- គណនេយ្យករត្រូវតែអនុវត្តន៍តាមផែនការដែលក្រុមហ៊ុនឬអ្នកគ្រប់គ្រងបានកំណត់ក្នុងដំណើរការនៃការគ្រប់គ្រងចំណូលនេះ
- រាល់ចំណូលដែលទទួលបានទាំងអស់ ត្រូវបានរក្សាទុកនៅក្នុងធនាគារដើម្បីធានាបាននូវសុវត្ថិភាព និងងាយស្រួលក្នុងការគ្រប់គ្រង
- រៀបចំប្រព័ន្ធគ្រប់គ្រងចំណូលឱ្យបានត្រឹមត្រូវមិនថាការកត់ត្រាដោយដៃក្តីឬដោយប្រើប្រព័ន្ធកុំព្យូទ័រក្តីគឺទាមទារឱ្យមានភាពច្បាស់លាស់។ តែដើម្បីឱ្យកាន់តែមានភាពងាយស្រួលយើងគួរកត់ត្រាដោយប្រើប្រព័ន្ធកុំព្យូទ័រតាមរយៈកម្មវិធី QuickBooks
- ធ្វើការបែងចែករវាងចំណូលនិងចំណាយឱ្យដាច់ពីគ្នាកុំឱ្យច្រឡំគ្នាដើម្បីងាយស្រួលក្នុងការកត់ត្រាក្នុងប្រព័ន្ធកុំព្យូទ័រ។ ម្យ៉ាងទៀតងាយស្រួលក្នុងការតាមដាននូវដំណើរការប្រតិបត្តិការចំណូលចំណាយទាំងអស់ដែលយើបានកត់ត្រា និងងាយស្រួលនៅពេលដំឡើងរបាយការណ៍ហិរញ្ញវត្ថុនៅពេលចុងខែ ឬចុងឆ្នាំ។
- រាល់ចំណូលទាំងអស់ដែលទទួលបានត្រូវមានសក្ខីបត្របញ្ជាក់ ឱ្យបានត្រឹមត្រូវជៀសវាងការកិបកេង ឬភ័ន្តច្រលំផ្សេងៗ។
- រាល់ចំណាយផ្សេងៗទាំងអស់របស់ក្រុមហ៊ុនក៏ត្រូវមានវិក័យបត្របញ្ជាក់ដូចគ្នា ដើម្បីឱ្យប្រាកដថាគ្មានការដកប្រាក់យកទៅប្រើប្រាស់ទៅលើចំណាយផ្សេងៗដែលអ្នកគ្រប់គ្រងមិនបានអនុម័ត។
- ត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់នូវការងារនិងតួនាទីរបស់បុគ្គលិកផ្នែកគ្រប់គ្រងប្រាក់ចំណូលទាំងអ្នកដែលត្រួតពិនិត្យក្តីទាំងគណនេយ្យករក្តី ដើម្បីឱ្យពួកគាត់បំពេញនូវតួនាទីរបស់គាត់បានដោយរលូន។

ខាងក្រោមនេះគឺជាការបែងចែកតួនាទីរបស់អ្នកគ្រប់គ្រង និងគណនេយ្យករ៖

**១. តួនាទីអ្នកគ្រប់គ្រង**

អ្នកគ្រប់គ្រងត្រូវរៀបចំចាត់ចែងផែនការក្នុងការគ្រង់គ្រងចំណូលថាត្រូវរៀបចំបែបណាដើម្បី ងាយស្រួលនិងមានគុណភាពដើម្បីឱ្យគណនេយ្យករយកទៅអនុវត្តតាមក្រោយ។ ម្យ៉ាងទៀត អ្នកគ្រប់គ្រងត្រូវ ពិនិត្យឡើងវិញទាំងអស់ឱ្យម៉ត់ចត់រាល់ការងារ ដែលគណនេយ្យករបានធ្វើហើយដើម្បីឱ្យកាន់តែមាន ភាពជឿ

ដាក់ថាទិន្នន័យទាំងនោះមិនបានខ្វះខាត ឬលើសលស់កន្លែងណាមួយ។ ខាងក្រោមនេះ គឺជាតួនាទី សំខាន់ៗរបស់អ្នកគ្រប់គ្រងក្នុងការគ្រប់គ្រងអាជីវកម្ម ដើម្បីឱ្យមានភាពល្អប្រសើរ និងរីកចម្រើន។

1. **ការធ្វើផែនការ**(Planning) ជាការកំណត់ផែនការនិងជ្រើសរើសនូវទិសដៅសម្រាប់អនុវត្តន៍ដើម្បីសម្រេចនូវគោលបំណងរបស់ក្រុមហ៊ុន។
2. **ការចាត់ចែង**(Organizing) ជាការបែងចែកនិយោជិតទៅតាមផ្នែកនីមួយៗឱ្យបានត្រឹមត្រូវទៅតាមការចាត់ចែង និងរៀបចំទុក។
3. **ការគ្រប់គ្រងធនធានមនុស្ស**(Human Resource management) ដំណើរការនៃការគ្រប់គ្រងមួយដែលត្រូវធ្វើការវាស់ស្ទង់នូវសមត្ថភាពនិយោជិត និងវាយតម្លៃទៅតាមស្ថានភាពជាក់ស្តែង
4. **ការដឹកនាំ**(Leading) ជាដំណើរការនៃការដឹកនាំបុគ្គលិកឱ្យអនុវត្តតាមផែនការដែលបានគ្រោងទុកដើម្បីឱ្យទទួលបានជោគជ័យ។
5. **ការត្រួតពិនិត្យ**(Controlling) ជាដំណើរការនៃការត្រួតពិនិត្យទៅលើសមិទ្ធផលដែលទទួលបាន ថាតើដូចដេលអ្វីដែលក្រុមហ៊ុនបានព្យាករណ៍ទុកហើយឬនៅ។

### ២. តួនាទីគណនេយ្យករ

- Planning and Budget (ធ្វើផែនការ និងរៀបចំថវិកា)ជាទូទៅម្ចាស់អជីវកម្មតែងមានគម្រោងសម្រាប់អជីវកម្មរបស់គាត់ ហើយអ្នកអនុវត្ត គឺជាគណនេយ្យករ ព្រោះនៅពេលដែលចាប់ផ្តើម ធ្វើគណនេយ្យករគឺជាអ្នកសម្លឹងមើល និងរំពឹងទុកអំពីកំណើនសេដ្ឋកិច្ចថាអាចមានការកើន ឡើង ឬថយចុះ ដូច្នេះគណនេយ្យករ ត្រូវស្វែងយល់ឱ្យបានច្រើនអំពី ស្ថានភាពសេដ្ឋកិច្ច
- គ្រប់គ្រងបញ្ជីសាច់ប្រាក់ចំពោះផ្នែកគណនេយ្យគឺក្រុមហ៊ុនមានជាប្រព័ន្ធកុំព្យូទ័រផ្ទាល់សម្រាប់ ធ្វើការកត់ត្រារាល់ប្រតិបត្តិការទាំងអស់ដែលកើតឡើងទៅតាមស្តង់ដារគណនេយ្យ។ បញ្ជីគ្រប់គ្រង សាច់ប្រាក់គឺជាបញ្ជីមួយដែលគណនេយ្យករត្រូវកត់ត្រាដោយផ្ទាល់ទៅលើ ប្រតិបត្តិការសាច់ប្រាក់ ដែលមានក្នុងសក្ខីបត្រចំណូលនិងចំណាយ ប្រចាំថ្ងៃដោយ បែងចែកគ្នា ឱ្យច្បាស់លាស់រវាងចំណូល និងចំណាយនេះដើម្បីងាយស្រួលក្នុងការតាមដាន និងគ្រប់គ្រងបានងាយស្រួល។
- ធ្វើការបិទបញ្ជីជារៀងរាល់ចុងខែគណនេយ្យករត្រូវធ្វើការបិទបញ្ជីដើម្បីឱ្យដឹងពីចំណេញខាតរបស់ក្រុមហ៊ុនក្នុងការកត់ត្រារយៈពេលមួយខែកន្លងមក
- ដំឡើងរបាយការណ៍ហិរញ្ញវត្ថុ(FinancialStatement) ដើម្បីដឹងពីទ្រព្យសកម្ម ទុន បំណុល និងចំណេញខាតជាដើមរបស់ក្រុមហ៊ុនជូនដល់អ្នកគ្រប់គ្រង។ របាយការណ៍ហិរញ្ញវត្ថុគេដំឡើងនៅពេលចុងខែ ឬចុងឆ្នាំដើម្បីបូកសរុបទិន្នន័យទាំងអស់ដែលបានកត់ត្រាកន្លងមក។

ក្នុងនាមយើងជាគណនេយ្យករយើងត្រូវស្វែងយល់ថា តើប្រាក់ដែលបានចំណាយធំច្រើនជាងគេបំផុតទៅលើអ្វី? តើប្រភពចំណូលធំបំផុតរបស់បានមកពីអ្វី? ការត្រួតពិនិត្យលើចំណុចទាំងនេះនឹងធ្វើឱ្យយើងអាចត្រៀមខ្លួនរួចរាល់ក្នុងការស្វែងរកប្រភពឬការចាត់ចែងប្រាក់ចំណូលសម្រាប់ឆ្នាំបន្ទាប់ ឱ្យមានប្រសិទ្ធភាពជាងមុន។ជាងនេះទៅទៀតយើងត្រូវពិនិត្យមើលថាប្រសិនបើអាជីវកម្មរបស់យើង ធ្លាក់ចុះ តើយើងគួរមានវិធីសាស្ត្រអ្វីដើម្បីស្វែងរកប្រាក់ចំណូលឡើងវិញ? បង្កើតគំនិតថ្មីៗដើម្បីឱ្យ ប្រាក់ចំណូលកើនឡើងបានច្រើនជាងមុន។ ហើយត្រូវតែប្រុងប្រយ័ត្នដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុ មានប្រសិទ្ធភាព។

## ៣.៤ បញ្ហាប្រឈមក្នុងការគ្រប់គ្រងប្រាក់ចំណូល

ក្រុមហ៊ុនស្រាបៀរអង្គរ គឺជាក្រុមហ៊ុនស្រាបៀរមួយដែលល្បីឈ្មោះជាយូរណាស់មកហើយ ហើយក៏ទទួលបានការគាំទ្រពីសំណាក់អតិថិជន ជាច្រើននៅក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗផង ដែរ។ ក្រុមហ៊ុននេះអាចរកប្រាក់ចំណូលបានយ៉ាងច្រើនក្នុងការលក់ផលិតផលរបស់ខ្លួន។ ស្រាបៀរអង្គរ គឺជាផលិតផលមួយដែលឈានមុខគេក្នុងចំណោមផលិតផលដទៃទៀតជាច្រើន ដែលទទួលបាន ការពេញនិយមខ្លាំងនៅលើទីផ្សារ។ ទាំងនេះគឺដោយសារក្រុមហ៊ុនបានរៀបចំ ប្រព័ន្ធគ្រប់គ្រងបានល្អ និងមានប្រសិទ្ធភាព។ ប៉ុន្តែទន្ទឹមនឹងភាពរីកចម្រើនភាពជោគជ័យនេះផងដែរ យើងក៏ឃើញថា ក្រុមហ៊ុនបានជួបនូវបញ្ហាមួយចំនួនដែលកើតឡើងក្នុងដំណើរការនៃការគ្រប់គ្រងផងដែរដូចជា៖

### ៣.៤.១ ប្រព័ន្ធគ្រប់គ្រងក្នុងក្រុមហ៊ុន

ទោះបីជាក្នុងក្រុមហ៊ុនបានរៀបចំប្រព័ន្ធការគ្រប់គ្រងទុកជាមុនយ៉ាងណាក៏ដោយក៏ការអនុវត្តនៅមិនទាន់មានភាពល្អប្រសើរទាំងស្រុងនៅឡើយទេ ព្រោះជាទូទៅវាតែងមានកង្វះខាតផ្សេងៗដែលកើតឡើងដោយចេតនាក្តី និងអចេតនាក្តីដូចជា៖

- ការគ្រប់គ្រងលំហូរសាច់ប្រាក់មិនបានល្អ
- ប្រព័ន្ធនៃការគ្រប់គ្រងប្រាក់ចំណូលពេលខ្លះនៅមានបញ្ហាដោយសារកំហុសអចេតនាមួយចំនួនរបស់គណនេយ្យករឬគណនេយ្យករ មិនបានអនុវត្តន៍តាមស្តង់ដារគណនេយ្យ និងផែនការដែលអ្នកគ្រប់គ្រងបានកំណត់ឱ្យបានម៉ត់ចត់
- ម្យ៉ាងទៀតវាអាចបណ្តាលមកពីការដំឡើងប្រព័ន្ធអេឡិចត្រូនិចឬប្រព័ន្ធកុំព្យូទ័រមិនទាន់មានភាពរលូនដែលមិនអាចឱ្យមានភាពស្រួលក្នុងការកត់ត្រាប្រតិបត្តិការ ផ្សេងៗជាដើម
- អ្នកគ្រប់គ្រងនៅមានភាពធូរលុងចំពោះនិយោជិតដែលជាការធ្វេសប្រហែលមួយធ្វើឱ្យនិយោជិតខ្វះការប្រឹងប្រែង ដើម្បីបំពេញការងារឱ្យអស់ពីលទ្ធភាព និងសមត្ថភាព
- ភាពគ្មានទំនួលខុសត្រូវរបស់បុគ្គលិកមួយចំនួនក៏ជាកត្តាមួយសំខាន់ដែលអ្នកគ្រប់គ្រងគួរធ្វើការកែលម្អជៀសវាងការខូចផលប្រយោជន៍រួម
- ចំណូលដែលទទួលបានមកត្រូវយកមកផ្គត់ផ្គង់វិញទៅលើចំណាយមួយចំនួនផ្សេងៗក្នុងក្រុមហ៊ុន ដូចជាត្រូវចំណាយទៅលើការទិញវត្ថុធាតុដើមដើម្បីយកមកដំណើរការក្នុងខ្សែសង្វាក់ផលិតកម្ម វិញជាដើម ការចំណាយលើប្រាក់ខែបុគ្គលិក ជួលទីតាំង ថ្លៃទឹកភ្លើងប្រចាំខែ បង់ពន្ធជូនរដ្ឋ និងចំណាយ ផ្សេងៗទៀត(ពេលខ្លះវាអាចនឹងមិនសមាមាត្រគ្នារវាងចំណូលនិងចំណាយ)
- បើសិនជាក្រុមហ៊ុនមិនបានរៀបចំគម្រោងប្រាក់ចំណូលឱ្យបានច្បាស់លាស់ទេវាអាច នឹងមានបញ្ហាប្រឈមដោយសារការប្រើប្រាស់ថវិកាចំណាយហួសកម្រិតមិនត្រូវតាមស្ថានការណ៍ ហើយក្រុមហ៊ុននឹងមានហានិភ័យសាច់ប្រាក់
- ប្រសិនបើបរិមាណនៃការលក់ផលិតផលមានការប្រែប្រួលឬការលក់មានការធ្លាក់ចុះនោះចំណូលដែលទទួលបានក៏ប្រែប្រួលទៅតាមបរិមាណនៃការលក់។ វាជាកត្តាមួយដ៏សំខាន់ក្នុងចំណោម កត្តាជាច្រើនផ្សេងទៀតដែលអ្នកគ្រប់គ្រងត្រូវមានវិធីសាស្ត្រក្នុងការកែលម្អ និងទប់ទល់ក្នុងករណី បើ

មានការធ្លាប់ចុះនៃការលក់ផលិតផលនេះពិតមែន និងត្រូវចេះប្រមាណមុននឹងចំណាយទៅ លើអ្វីមួយជៀសវាងការប្រើប្រាស់ថវិការរបស់យើងកាន់តែកើនឡើង

- កាត់បន្ថយការលក់ជំពាក់ឱ្យអតិថិជន កុំឱ្យអតិថិជនជំពាក់មានចំនួនច្រើនពេកដើម្បីជៀសវាងកុំ ឱ្យយើងពិបាកក្នុងការគ្រប់គ្រងព្រោះបើក្រុមហ៊ុនមិនទទួលបានចំណូលគ្រប់គ្រងទេវាអាចធ្វើឱ្យចំណាយកើនឡើងខ្ពស់

ម្យ៉ាងទៀតក្រៅពីបញ្ហាមួយចំនួនខាងលើដែលទាក់ទងនឹងការគ្រប់គ្រងចំណូលនេះហើយ ក្រុមហ៊ុនក៏នៅមានបញ្ហាមួយចំនួនផ្សេងទៀតដែលកើតមានក្នុងក្រុមហ៊ុនដែលវាក៏អាចធ្វើឱ្យមានផលប៉ះពាល់មួយចំនួនតូចផងដែរដូចជា៖

**ក. បញ្ហាខាងក្នុង**

- បុគ្គលិក៖ បុគ្គលិកខ្លះមានសមត្ថភាពគ្រប់គ្រាន់ស្របទៅតាមការចង់បានរបស់ក្រុមហ៊ុន ចំណែក ឯបុគ្គលិកខ្លះទៀតសមត្ថភាពរបស់គាត់នៅមានកម្រិត។
- បុគ្គលិកមួយចំនួន បាននាំគ្នាធ្វើកូដកម្មសុំឱ្យក្រុមហ៊ុនដំឡើងប្រាក់ខែឱ្យពួកគេដោយសារប្រាក់ខែដែលពួកគេទទួលបានមិនសមស្របនឹងកម្លាំងពលកម្ម
- ការធ្វេសប្រហែសមួយចំនួនរបស់បុគ្គលិកក្នុងពេលបំពេញការងារដែលបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិ ឬសម្ភារៈផ្សេងៗរបស់ក្រុមហ៊ុន
- ខ្វះការប្រាស្រ័យទាក់ទងល្អនឹងគ្នាទៅវិញទៅមកចំពោះបុគ្គលិកមួយចំនួន
- ទំនួលខុសត្រូវរបស់ពួកគេនៅមានកម្រិតទាប ជាហេតុធ្វើឱ្យលទ្ធផលការងារនៅមានការខ្វះខាត និងមានភាពខុសឆ្គងមួយចំនួន

**ខ. បញ្ហាខាងក្រៅ**

- ការប្រកួតប្រជែង៖ ដោយសារបច្ចុប្បន្នមានផលិតផលច្រើនប្រភេទ ច្រើនម៉ាក ទើបធ្វើឱ្យក្រុមហ៊ុននីមួយៗត្រូវមានការប្រកួតប្រជែងគ្នាដើម្បីស្វែងរកទីផ្សារឱ្យបានខ្ពស់រៀងៗខ្លួនដើម្បីទាមទារការ ចាប់អារម្មណ៍ពីសំណាក់អតិថិជនទាំងអស់ ទាំងនៅក្នុងស្រុក និងក្រៅស្រុក។ វាជាបញ្ហាដែល ក្រុមហ៊ុនត្រូវមានការគិតគូរឱ្យបានប្រុងប្រយ័ត្នទាក់ទងនឹងផលិតផលរបស់ខ្លួនទៅលើបញ្ហារឿង គុណភាពរចនាបថតម្លៃសេវាកម្ម និងបញ្ហាមួយចំនួនទៀត ដើម្បីយកឈ្នះលើដៃគូប្រកួតប្រជែង
- ការផ្សព្វផ្សាយ៖ ការផ្សព្វផ្សាយនៅមិនទាន់មានភាពទូលំទូលាយ ជួនកាលការផ្សព្វផ្សាយមាន នៅតែតំបន់ទីប្រជុំជន ដែលមានមនុស្សច្រើនតែប៉ុណ្ណោះ។ ដូចនេះក្រុមហ៊ុនគួរតែពង្រឹងប្រព័ន្ធផ្សព្វផ្សាយឱ្យបានកាន់តែច្រើនទៅតាមដែលអាចធ្វើបាន ក្នុងគោលបំណងផ្សព្វផ្សាយពីផលិតផលរបស់ខ្លួនឱ្យបានដល់គោលដៅអតិថិជន

ជាទូទៅគ្រប់ដំណើរការអាជីវកម្មទាំងអស់តែងតែជួបប្រទះនូវបញ្ហាប្រឈមផ្សេងៗពីគ្នាដែលមិនអាចជៀសផុតបាន។វាជាកត្តាសំខាន់ដែលទាមទារឱ្យម្ចាស់អាជីវកម្មនិងអ្នកគ្រប់គ្រងស្វែងរកដំណោះស្រាយដើម្បីទប់ស្កាត់រាល់បញ្ហាទាំងនេះ ជាពិសេសគឺបញ្ហាក្នុងការគ្រប់គ្រងចំណូលតែម្តង។

ដំណោះស្រាយមួយចំនួនដើម្បីធ្វើឱ្យក្រុមហ៊ុនកាន់តែមានតម្លាភាព៖

- ដោះស្រាយបញ្ហាលំហូរសាច់ប្រាក់បច្ចុប្បន្ន

- រៀបចំប្រព័ន្ធគ្រប់គ្រងទាំងអស់ឱ្យបានត្រឹមត្រូវ
- ភ្ជាប់ទំនាក់ទំនងជាមួយអតិថិជន និងទីផ្សារថ្មីៗ
- ចំណាយពេលដើម្បីស្វែងរកឱកាសថ្មីៗសម្រាប់អាជីវកម្មរបស់យើង។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង
# និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយរបស់ក្រុមហ៊ុនពិតជាមានសារៈសំខាន់ណាស់ក្នុងការវាយតម្លៃពីស្ថានភាពទូទៅរបស់ក្រុមហ៊ុនវាស់វែងពីដំណើរការនិងសកម្មភាពផ្សេងៗក្នុងក្រុមហ៊ុន។ ក្រោយពី បានសិក្សាស្រាវជ្រាវ រួចមកយើងខ្ញុំក៏បានរកឃើញនូវចំណុចខ្លាំង ចំណុចខ្សោយមួយចំនួនរបស់ក្រុមហ៊ុនដូចជា៖

## ៤.១ ការវិភាគចំណុចខ្លាំង

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវទាក់ទង នឹងប្រធានបទការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន ស្រាបៀរអង្គររួចមកយើងឃើញថា៖

- ក្រុមហ៊ុនមានប្រព័ន្ធគ្រប់គ្រងត្រឹមត្រូវទៅលើរបាយការណ៍ចំណូលទាំងអស់ ហើយបានអនុវត្តន៍តាមស្តង់ដារគណនេយ្យ ដែលធ្វើអោយក្រុមហ៊ុនមិនងាយមានការខាតបង់
- រាល់ការកត់ត្រាប្រតិបត្តិការទាំងអស់ គឺផ្អែកទៅលើសក្ខីបត្រ មិនមានការក្លែងបន្លំ ព្រោះអ្នកគ្រប់គ្រងផ្តោតលើភាពច្បាស់លាស់ខ្ពស់
- ការកត់ត្រាប្រើប្រាស់តាមប្រព័ន្ធកុំព្យូទ័រព្រោះវាមានភាពងាយស្រួលក្នុងការតាមដានរាល់ប្រតិបត្តិការទាំងអស់ និងងាយស្រួលក្នុងការគ្រប់គ្រងចំណូល
- ក្រុមហ៊ុនបានប្រើប្រាស់នូវកម្មវិធីគណនេយ្យកុំព្យូទ័រតាមប្រព័ន្ធQuickBooksហើយមានការត្រួតពិនិត្យយ៉ាងត្រឹមត្រូវពីប្រធានផ្នែក ដើម្បីធានាបាននូវទំនុកចិត្តច្បាស់លាស់
- ចំណូលដែលទទួលបានជាសាច់ប្រាក់ទាំងអស់ត្រូវបានបញ្ជូនទៅធនាគារដើម្បីរក្សាទុកនិង ការពារសុវត្ថិភាព
- រាល់ការចំណាយទាំងអស់ត្រូវឆ្លងកាត់ការអនុញ្ញាតពីអ្នកគ្រប់គ្រងដោយមានការចុះហត្ថលេខាជាមុនហើយត្រូវមានវិក័យបត្រមកបញ្ជាក់ដើម្បីធ្វើជាឯកសារក្នុងការកត់ត្រាប្រតិបត្តិការ
- រាល់របាយការណ៍ និងឯកសារហិរញ្ញវត្ថុទាំងអស់ត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវ
- ក្រុមហ៊ុនមានប្រព័ន្ធត្រួតពិនិត្យយ៉ាងត្រឹមត្រូវទៅតាមវិធីសាស្ត្រនិងផែនការដែលក្រុមហ៊ុនបានកំណត់ទុក
- ការគ្រប់គ្រងលើសកម្មភាពការងារ និងការបំរើសេវាកម្មជូនដល់អតិថិជនមានលក្ខណៈល្អប្រសើរ

## ៤.២ ការវិភាគចំណុចខ្សោយ

ទោះបីជាក្រុមហ៊ុនមានផែនការក្នុងការគ្រប់គ្រងយ៉ាងណាក៏ដោយក៏នៅឃើញមានចំណុចខ្វះខាតដោយអចេតនាមួយចំនួនផងដែរដូចជា៖

- ក្រុមហ៊ុនមិនទាន់មានការរៀបចំគម្រោងថវិកាចំណូលបានច្បាស់លាស់នៅឡើយទេ ជាហេតុធ្វើឱ្យការគ្រប់គ្រងចំណូលនៅមានភាពអោក់អួល

- ការភ័ន្តច្រឡំរបស់គណនេយ្យករក្នុងពេលកត់ត្រាប្រតិបត្តិការចំណូលចំណាយផ្សេងៗ ឬបាត់សក្ខីបត្រណាមួយ ជាដើមដែលជាហេតុអាចធ្វើអោយមានបញ្ហាកើតឡើង
- ការមិនអនុវត្តន៍ទៅតាមស្តង់ដារគណនេយ្យនូវចំណុចមួយចំនួនតូច ក៏ធ្វើអោយមានផលប៉ះពាល់ដល់ក្រុមហ៊ុនផងដែរ
- ក្រុមហ៊ុនគួរតែកាត់បន្ថយនូវចំណាយមួយចំនួនដែលមិនសូវចាំបាច់ចោលដើម្បីកុំឱ្យចំណាយកាន់តែកើនឡើងការគ្រប់គ្រងបំណុលអតិថិជនមានរយៈពេលវែងពេក។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# ជំពូកទី៥

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

## ៥.១ សេចក្ដីសន្និដ្ឋាន

ក្រោយពីសិក្សាស្រាវជ្រាវយ៉ាងលម្អិតទៅលើប្រធាន**"ការគ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ"** រួចមកបានបង្ហាញឱ្យយើងខ្ញុំបានយល់ដឹងកាន់តែច្រើនពីរបៀបនៃការគ្រប់គ្រងចំណូលនិងវិធីសាស្ត្រក្នុង ការរៀបចំផែនការគ្រប់គ្រងមួយចំនួនផ្សេងទៀត។ ម្យ៉ាងទៀតក៏បានបង្ហាញឱ្យយើងដឹងពីចំណុចខ្លាំង និង ចំណុចខ្សោយរបស់ក្រុមហ៊ុនដែលជាផ្នែកមួយក្នុងការដែលយើងយកមកអនុវត្តតាមនូវចំណុចល្អៗនិងកែ លម្អឬបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួនទៀតឱ្យកាន់តែល្អប្រសើរឡើងនិងកាន់តែមានប្រសិទ្ធភាព។

តាមរយៈការស្រាវជ្រាវនេះដែរបានបង្ហាញឱ្យយើងឃើញថាក្រុមហ៊ុនស្រាបៀរអង្គរជាក្រុមហ៊ុនមួយដែលអាចដំណើរការបានយ៉ាងរលូន ព្រមទាំងទទួលបានការគាំទ្រជាច្រើនពីសំណាក់អតិថិជនទាំងក្នុងស្រុក និងក្រៅស្រុក។ ក្រុមហ៊ុនក៏បានខិតខំ ព្យាយាមផ្គត់ផ្គង់ផលិតផលជូនដល់អតិថិជនទៅតាមតម្រូវការ និង ផ្ដល់សេវាកម្មយ៉ាងល្អ។ នេះបញ្ជាក់ឱ្យឃើញថាក្រុមហ៊ុនមានការគ្រប់គ្រងផ្នែកធនធានមនុស្ស ផ្នែក ផលិតកម្ម និងផ្នែកផ្សេងៗទៀតបានល្អប្រសើរ។

ដូចនេះយើងអាចសន្និដ្ឋានបានថាគម្រោងនៃការគ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុនគឺមានប្រសិទ្ធភាពល្អព្រោះមានការកត់ត្រាត្រឹមត្រូវមានការត្រួតពិនិត្យច្បាស់លាស់ពីអ្នកគ្រប់គ្រង។ជាពិសេសបុគ្គលិកគ្រប់ផ្នែកទាំងអស់បានបំពេញតួនាទីរបស់ខ្លួនបានយ៉ាងល្អដែលអាចជួយឱ្យដំណើរការក្រុមហ៊ុនកាន់តែរលូនទៅមុខជាលំដាប់។

ប៉ុន្តែទោះបីជាក្រុមហ៊ុននេះមានការរៀបចំផែនការការគ្រប់គ្រងបានយ៉ាងមានប្រសិទ្ធភាពខ្ពស់ យ៉ាងណាក៏ដោយក៏វានៅតែមានចំណុចខ្វះខាតមួយចំនួនតូចផងដែរដូចជាការធ្វេសប្រហែសក្នុងការ កត់ត្រាប្រតិបត្តិការនិងការបែងចែកចំណូលចំណាយមិនបានច្បាស់លាស់ជាដើម។ តែបញ្ហាតូចនេះ ក៏យើងមិនគួរមើលរំលងដែរព្រោះវាអាចជាបញ្ហាធំនៅថ្ងៃខាងមុខក៏ថាបាន។ ដូចនេះយើងគួរមានវិធីសាស្ត្រ ក្នុងការទប់ស្កាត់បញ្ហាទាំងនេះឱ្យបានល្អត្រូវចេះសហការគ្នាចេះយោគយល់គ្នាទៅវិញទៅមក និងផ្ដល់ យោបល់គ្នាដើម្បីដោះស្រាយបញ្ហាទាំងនេះទើបក្រុមហ៊ុនកាន់តែមានភាពរីកចម្រើន។

សរុបសេចក្ដីមកយើងអាចសន្និដ្ឋានបានថាថ្វីត្បិតតែការគ្រប់គ្រងមានទាំងគុណសម្បត្តិ និងគុណវិបត្តិ យ៉ាងណាក៏ដោយក៏ក្រុមហ៊ុននូវតែអាចសម្រេចបាននូវប្រសិទ្ធភាព និងសមិទ្ធផលទាំងផ្នែកផលិត ផ្នែកសេវាកម្ម ផ្សេងៗបានយ៉ាងរលូនឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់និយោជិតក្នុងក្រុមហ៊ុនទាំងមូល។

## ៥.២ ការផ្ដល់អនុសាសន៍

ឆ្លងតាមការសន្និដ្ឋានលើការស្រាវជ្រាវទាក់ទង នឹងប្រធានបទខាងលើរួចមកយើងសង្កេតឃើញថាក្រុមហ៊ុនមានចំណុចខ្លាំងជាច្រើនក្នុងការគ្រប់គ្រង តែក៏នៅមានចំណុចខ្វះខាតមួយចំនួនតូចផងដែរ ដែលគួរតែធ្វើការកែលម្អឱ្យបានកាន់តែប្រសើរឡើងក្នុងការគ្រប់គ្រងចំណូលមានដូចខាងក្រោម៖

- ត្រូវរៀបចំគម្រោងថវិការចំណូលឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងការអនុវត្ត
- គណនេយ្យករត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យកាន់តែប្រសើរឡើងហើយត្រូវអនុវត្តន៍តាមផែនការដែលក្រុមហ៊ុនបានកំណត់ឱ្យដើម្បី ឱ្យដំណើរការក្នុងការគ្រប់គ្រងប្រាក់ចំណូលកាន់តែមាន ប្រសិទ្ធភាពត្រូវគ្រប់គ្រងថ្លៃដើមឱ្យបានល្អមុននឹងស្នើទិញអ្វីមួយត្រូវមានការចុះហត្ថលេខាពីអ្នក គ្រប់គ្រងឱ្យបានច្បាស់លាស់ ដើម្បីកុំឱ្យមានការក្លែងបន្លំពីបុគ្គលមួយចំនួនហើយក្រុមហ៊ុនគួរតែកាត់ បន្ថយនូវចំណាយ មួយចំនួនដែលមិនសូវចាំបាច់ និងត្រូវចេះសន្សំសំចៃ រាល់សម្ភារៈប្រើប្រាស់ផ្សេងៗ ក្នុងក្រុមហ៊ុនត្រូវប្រើឱ្យអស់ពីលទ្ធភាពដើម្បី កុំឱ្យការចំណាយកាន់តែកើនឡើងខ្ពស់។

# ឯកសារយោង

# ឯកសារយោង

- ❖ សាស្ត្រាចារ្យ បណ្ឌិត កង ឱម (វិធីសាស្ត្រនៃការស្រាវជ្រាវ Research Methodology)
- ❖ ដកស្រង់ពីឯកសារ សារណានៅក្នុងបណ្ណាល័យនៃវិទ្យាស្ថានវ៉ាន់ដា របស់និស្សិតដែលបានបញ្ចប់ឆ្នាំសិក្សាមុនៗ
- ❖ សួរយោបល់ពីសាស្ត្រាចារ្យ និងសិស្សច្បងមុនៗ
- ❖ ស្រាវជ្រាវរកតាមរយៈ Google, Websiteដែលទាក់ទងនិងប្រភពចំណូល និងការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ
- ❖ របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រ របស់និស្សិតជំនាន់ទី១៨ ស្ដីពី "*ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុនស្រាបៀរអង្គរ*"។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ


ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ
Heineken
ជំនាញ: គណនេយ្យ
PHNOM PENH, 2020


ក្រសួងអប់រំយុវជន និង កីឡា
MINISTR OF EDUCATION YOUTH AND SPORTS
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ
ការគ្រប់គ្រងប្រាក់ចំណូលរបស់ក្រុមហ៊ុន
ស្រាបៀរអង្គរ
REVENUE MANAGEMENT OF
ANGKOR BEER
ជំនាញ: គណនេយ្យ
រាជធានីភ្នំពេញ ឆ្នាំ២០២១
PHNOM PENH, 2021
Library/2021


Angkor

